# ការធ្វើឱ្យរឿងក្តីក្នុងស្រុកឱ្យស្របតាមបទដ្ឋានអន្តរជាតិ ការអនុវត្តយុត្តិសាស្ត្រនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងនីតិវិធីក្នុងស្រុក

ម៉ៃឃើល ជី. ខាណាវ៉ាស[1]

បើទោះបីជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា (អ.វ.ត.ក) បាន អនុម័តបង្កើតឲ្យមាននីតិវិធី និងយុត្តាធិការដោយឡែក ផ្សេងពីការអនុវត្តរបស់តុលាការជាតិ ដើម្បីយក មកជំនុំជម្រះបទឧក្រិដ្ឋកម្មអន្តរជាតិដែលកើតឡើងក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក៏ដោយ ក៏តុលាការនេះ នៅតែមានទម្រង់ជាតុលាការជាតិដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា និងរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការ ។ ហេតុដូច្នេះហើយ ទើបគេឃើញយុត្តិសាស្ត្រ និងនីតិវិធី ដែលប្រើប្រាស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានដូចគ្នាទៅនឹងការអនុវត្តនៅក្នុង តុលាការជាតិ ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នជាច្រើនលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សទាក់ទង នឹងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងថែមទាំងបានបញ្ចូលអនុសញ្ញាទាំងនោះចូលទៅ ក្នុងប្រព័ន្ធច្បាប់ជាតិតាមរយៈរដ្ឋធម្មនុញ្ញ ។ ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានត្បាញខ្លួនបញ្ចូលទៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការកម្ពុជា ដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជានឹងក្លាយជាគំរូសម្រាប់តុលាការជាតិ ដោយជួយបន្ថែមការយល់ដឹងពីកាតព្វកិច្ចទាំងឡាយ

[1] អតីតមេធាវីអន្តរជាតិការពារក្តី អៀង សារី នៅក្នុងសំណុំរឿង០០២ និងបច្ចុប្បន្នជាសហមេធាវីអន្តរជាតិតំណាងឲ្យ ជនសង្ស័យមួយរូបដែលពុំទាន់ត្រូវបានបញ្ចេញឈ្មោះនៅក្នុងសំណុំរឿង០០៣ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា ។ អត្ថបទនេះ ត្រូវបានកែសម្រួលមកពីអត្ថបទសង្ខេបសម្រាប់ធ្វើបទបង្ហាញ នៅក្នុងកិច្ចប្រជុំដែលរៀបចំដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និង គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិ មនុស្សកម្ពុជា ដែលហៅកាត់ថា (CHRAC) នៅថ្ងៃទី១៣ និងទី១៤ ខែកញ្ញា ឆ្នាំ២០១២ នៅសណ្ឋាគារ Raffles Hotel Le Royal ក្នុងទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ កិច្ចប្រជុំនោះធ្វើឡើងក្រោមប្រធានបទ : ទស្សនៈចម្រុះ អំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ អ្នកនិពន្ធសូមថ្លែងអំណរគុណចំពោះ កញ្ញា Anne Layton Sibree, ដែលជាអន្តេវាសិកនៃក្រុមការពារលោក អៀង សារី សម្រាប់ការជួយជ្រោមជ្រែងយ៉ាងសប្បុរស និងពុំអាចកាត់ថ្លៃបាន ។

នៃស្ថាប័នតុលាការ តាមរយៈការអនុវត្តគោលការណ៍អន្តរជាតិនៅក្នុងការធ្វើសេចក្តីវិនិច្ឆ័យជាប្រចាំថ្ងៃ ដោយប្រើប្រាស់ច្បាប់ក្នុងស្រុកដោយតុលាការជាតិ ។ ការនាំយករឿងក្តីក្នុងស្រុកមកអនុវត្តឲ្យស្របតាម គោលការណ៍អន្តរជាតិ តាមរយៈការប្រើប្រាស់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា រួមជាមួយនឹងវិធានការបន្ថែមផ្សេងៗទៀត អាចនឹងជួយលើកស្ទួយប្រព័ន្ធតុលាការកម្ពុជាមាន ភាពកាន់តែប្រសើរឡើង និងជំរុញដល់ការគោរពនីតិរដ្ឋ ។

១. សេចក្តីផ្តើម

២. អំណះអំណាងគាំទ្រសេចក្តីសន្និដ្ឋានដែរថាយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជាអាចយកមកអនុវត្តបាននៅក្នុងប្រព័ន្ធតុលាការជាតិរបស់កម្ពុជា

២.១. តួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមជាតុលាការ ក្នុងស្រុក

២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២.៣. ទំនាក់ទំនងនៃការអនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅកម្ពុជា

២.៤. លិខិតុបករណ៍គ្រប់គ្រងលើការអនុវត្ត និងដំណើរការរបស់អង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា

២.៤.១. កិច្ចព្រមព្រៀង

២.៤.២. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

២.៤.៣ វិធានផ្ទៃក្នុង

២.៤.៤. យុត្តិសាស្ត្រនៃតុលាការអន្តរជាតិ និងតុលាការអន្តរតូបនីយកម្ម

២.៥. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាតុលាការគំរូ

៣. ការទទួលស្គាល់នូវភាពទន់ខ្សោយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៤. ប្រើប្រាស់ចំណុចវិជ្ជមានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីធ្វើឲ្យ ទៅជាប្រយោជន៍

៥. បន្ទាប់ពីទីនេះ តើចំណុចណាដែលត្រូវបន្តដំណើរទៅ?

៦. សំឡេងគ្រែបន្ទឺហៅមេធាវីការពារជនជាប់ចោទ

# ១. សេចក្តីផ្តើម

អ.វ.ត.ក គឺជាអង្គជំនុំជម្រះវិសាមញ្ញមួយដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការរបស់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង ដោយមានកិច្ចសហការពីសំណាក់អង្គការសហប្រជាជាតិ ដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋកម្មទាំងថ្នាក់ជាតិ និងអន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅប្រទេសកម្ពុជានៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ លិខិតបទដ្ឋានមួយចំនួនដែលរៀបចំឡើងដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងចែងអំពីតួនាទី និងភារកិច្ចដែលស្ថិតនៅក្រោមប្រព័ន្ធតុលាការជាតិ បានគាំទ្រសេចក្តីសន្និដ្ឋានដែរថា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាផ្នែកមួយដែលស្ថិតនៅក្រោមប្រព័ន្ធច្បាប់របស់កម្ពុជា ។ ហេតុដូច្នេះ យុត្តិសាស្ត្រទាំងនោះអាចយកមកប្រើប្រាស់បានដោយតុលាការជាតិ ។ លិខិតបទដ្ឋានទាំងនោះ រួមមាន៖ **ក)** លក្ខន្តិកៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាតុលាការជាតិ **ខ)** តួនាទីនៃរដ្ឋធម្មនុញ្ញ[២] ដែលតម្រូវជាពិសេសឲ្យតុលាការគ្រប់ជាន់ថ្នាក់ពិចារណាលើគោលការណ៍ច្បាប់អន្តរជាតិ នៅពេលណាដែលមានការប្រើប្រាស់ច្បាប់ជាតិ **គ)** ទំនាក់ទំនងរវាងការអនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា **ឃ)** ឥទ្ធិពលនៃលិខិតុបករណ៍ដទៃទៀត ដែលគ្រប់គ្រងលើកិច្ចដំណើរការ និងនីតិវិធីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[៣] ដែលបានក្លាយជាមូលដ្ឋានគ្រឹះនៅក្នុងនីតិវិធីជាតិ និងបំពេញបន្ថែមដោយគោលការណ៍អន្តរជាតិ **ង)** បំណងប្រាថ្នារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការបំពេញតួនាទីជាតុលាការ "គំរូ" នៃប្រទេសកម្ពុជា ដើម្បីលើកតម្កើងសមត្ថភាពស្ថាប័នតុលាការ និងដើម្បីលើកស្ទួយនីតិរដ្ឋ ។

ជាមួយនឹងលិខិតបទដ្ឋានសំខាន់ៗទាំងនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់នូវឱកាសជូនប្រជាជនកម្ពុជាដើម្បីឲ្យបានដឹងអំពីតួនាទី និងភារកិច្ចរបស់តុលាការមួយ ដែលបង្កើតឡើង

---

[២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣), វិសោធនកម្មនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។

[៣] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពាក់ព័ន្ធនឹងការកាត់ទោសតាមច្បាប់កម្ពុជាស្តីពីឧក្រិដ្ឋកម្មនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង"); ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើត"); វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, កំណែទី៨ (កែនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០១១) (វិធានផ្ទៃក្នុង") ។

ក្នុងគោលបំណងដើម្បីផ្តល់យុត្តិធម៌ ដែលប្រកបដោយខ្លឹមសារ និងត្រឹមត្រូវតាមនីតិវិធីច្បាប់ តាមរយៈការប្រើប្រាស់គោលការណ៍ និងបទដ្ឋានអន្តរជាតិ ។ បើទោះបីជា មានការខិតខំខ្លះខ្នែងក្នុងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់គ្រប់ភាគីក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅពុំទាន់បានគោរពតាមអ្វីដែលខ្លួនបានសន្យាថា នឹងអនុវត្តឲ្យបានខ្ជាប់ខ្ជួនរាល់បទដ្ឋាន និងនីតិវិធីទាំងនោះនៅឡើយ ។ មានសេចក្តីសម្រេចជាច្រើន ទាំងសេចក្តីសម្រេចលើអង្គហេតុ និងសេចក្តីសម្រេចទាក់ទងនឹងនីតិវិធី បានបើកចំហចំពោះការតវ៉ា និងការរិះគន់ដែលមិនគួរឲ្យស្វាគមន៍ ។[៤] អ្វីដែលគួរឲ្យព្រួយបារម្ភនោះ គឺការចោទថាមានអំពើពុករលួយ[៥] កើតឡើង ការជ្រាតជ្រែកផ្នែកនយោបាយ[៦] ការបរិហារពីអសមត្ថភាពក្នុងដំណើរការស៊ើបអង្កេតក្នុងរឿងក្តី ០០២[៧] និងការជំពាក់ជំពិនជាមួយនឹងការបំពេញការងារមិនបានត្រឹមត្រូវ អសមត្ថភាព និងកង្វះឯករាជភាពនៅក្នុងការស៊ើបអង្កេតពាក់ព័ន្ធនឹងរឿងក្តី ០០៣ និង ០០៤ ។[៨]

---

[៤] *សូមមើលសំណុំរឿងក្តី នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជ, ដីកាបង្គាប់ទៅក្រុមមេធាវីការពារក្តីរបស់ អៀង សារី ពាក់ព័ន្ធនឹងការដាក់សេចក្តីជំទាស់ជាបឋម (ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១) (តម្រូវឲ្យមេធាវីការពារក្តីរបស់ អៀង សារី សង្ខេបរាល់សេចក្តីជំទាស់បឋមរបស់ខ្លួនស្តីពីយុត្តាធិការមកត្រឹមចំនួន៣៥ទំព័រ); រឿងក្តីរបស់ នួន ជា, ០០២,១៩-០៩-២០០៧-អវតក/អជ, សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើឲ្យដកចេញលក្ខខណ្ឌតម្រូវទាក់ទងនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០) ។*

[៥] *សូមមើល* Michael Salibas, *ការចោទប្រកាន់ទាក់ទងនឹងអំពើពុករលួយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា; សេចក្តីសង្ខេប, បុកឃ្លាំមើលតុលាការកម្ពុជា (ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៩) (ឯកសារនេះមាននៅនឹងអ្នកនិពន្ធ)*; Alex Bates, *ដកស្រង់ចេញពីអត្ថបទ* *Transitional Justice in Cambodia: Analytical Report*, ATLAS Project/British Institute of International and Comparative Law, *នៅទំព័រ៥៨-៦០ (ខែតុលា ឆ្នាំ២០១០)* («Bates Report») ។

[៦] *សូមមើល* Bates Report, *កំណត់សម្គាល់ជើងទំព័រទី៥, ទំព័រ៥២-៥៨ ។*

[៧] *សូមមើល* Anne Heindel, "*Critical*" *Irregularities in Interview Procedures Highlighted During Witness Testimony*, *(ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១២), អាចរកបាននៅគេហទំព័រ* http://www.cambodiatribunal.org/sites/default/files/CTM%20Heindel%2012-08-30.pdf *(ចូលមើលចុងក្រោយនៅ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣) ។*

[៨] Open Society Justice Initiative, *Recent Developments at the Extraordinary Chambers of the Courts of Cambodia*, *ទំព័រ៥, ២០-៣០, (ខែកុម្ភៈ ឆ្នាំ២០១២) («របាយការណ៍* OSJI*), អាចរកបានតាមរយៈគេហទំព័រ* http://www.soros.org/sites/default/files/cambodia-eccc-20120233.pdf *(ចូលមើលចុងក្រោយនៅ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១២) ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានសំអាងលើភាពមិនប្រក្រតីមួយចំនួនដែលបានកើតឡើងក្នុងអំឡុងដំណើរការស៊ើបអង្កេតក្នុងរឿងក្តី ០០៣ និង ០០៤ ពាក់ព័ន្ធនឹងភាពអាចទទួលបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ពាក់ព័ន្ធនឹងរឿងក្តី ០០៤ ចៅក្រម* Lahuis *និង* Downing *បានអង្កេតឃើញថា «នៅពេលដែលខ្វះតម្លាភាពក្នុងកិច្ចដំណើរការនីតិវិធីនឹងមានផលប៉ះពាល់ចំពោះសិទ្ធិរបស់ភាគីដែលប្តឹងឧទ្ធរណ៍ដើម្បីបង្ហាញឲ្យអស់ពីសមត្ថភាពនៃសំណុំរឿងនោះ.. ពួកយើងត្រូវ*

ការអះអាងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជា "តុលាការគំរូ"[៩] គឺជាការគិតប្រាថ្នាលើសពីអ្វីដែលមើលឃើញជាក់ស្តែង ។ សេចក្តីសម្រេចមួយចំនួនដែលបានចេញដោយការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ (អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល) ហាក់បីដូចជាមានការរុញច្រានពីសំណាក់ឥទ្ធិពលនយោបាយ ដោយជំរុញ (ឬរារាំង ការចោទប្រកាន់ និងជំនុំជម្រះ ដូចដែលកំពុងកើតមាន) ឲ្យមានវប្បធម៌នៃការបញ្ចៀស និង/ឬ ការលាក់បាំង ។

ក៏ប៉ុន្តែ ដោយចៃដន្យ តុលាការនៅកម្ពុជាបានអនុវត្តគោលការណ៍សិទ្ធិមនុស្សអន្តរជាតិដែលបានរួមបញ្ចូលក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។[១០] បើទោះបីជា អង្គជំនុំជម្រះវិសាមញ្ញក្នុង

---

បានបង្ហឹឲ្យបកស្រាយពីចំណុចជាក់លាក់ចំពោះការកត់សម្គាល់នៃដីកាក្នុងសំណុំរឿង០០៤ ជូនភាគីដែលប្តឹងខទ្ទរណ៍ និងសហមេធាវីរបស់គាត់ ។" រឿងក្តី០០៤/០៧-០៩-២០០៩-អវតក/OCIJ (PTC 02), ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងខទ្ទរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបានលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill, មតិខ្វែងយោបល់របស់ចៅក្រម Lahuis និងចៅក្រម Downing កថាខណ្ឌទី៧ (ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១២) ។ សូមមើល សំណុំរឿង០០៣/០៧-០៩-២០០៩-ECCC/OCIJ (PTC 02), បណ្តឹងខទ្ទរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបានលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី RobertHamill, មតិខ្វែងយោបល់របស់ចៅក្រម Lahuis និងចៅក្រម Downing កថាខណ្ឌទី២ (ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១) ។

[៩] អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា នៅខណៈដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំមានអាណត្តិដោយផ្ទាល់ដើម្បីដោះស្រាយភាពចន្លោះប្រហោងនៃយន្តការជាតិដែលបង្កើតឡើងដើម្បីលើកកម្ពស់ឯករាជភាពរបស់តុលាការ "យ៉ាងណាក៏ដោយ ក្នុងនាមជាតុលាការគំរូ វាអាចដើរតួនាទីក្នុងការជ្រោមជ្រែង និងសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការការពារស្ថាប័ននៃឯករាជភាព និងសុចរិតភាពនៃប្រព័ន្ធតុលាការ ។" ក្នុងរឿងក្តី នួន ជា, ០០២/១៩-០៩-២០០៧-ECCC/TC, សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលស្នើសុំដកចៅក្រម និល ណុន និងសំណើសុំផ្សេងៗទៀត, កថាខណ្ឌទី១៨ (ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១) ("សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលស្នើសុំដកចៅក្រម និល ណុន") (ត្រូវការការបញ្ជាក់បន្ថែម) ។

[១០] សូមមើល, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដែលហៅកាត់ថា ("CCHR"), របាយការណ៍ប្រចាំឆមាសលើកទី៤ : សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ២០០៩-២០១១ (២០១២), អាចរកបាននៅគេហទំព័រ http://www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=81&id=5 (ចូលមើលលើកចុងក្រោយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២), ដោយកំណត់អំពីសិទ្ធិមួយចំនួនដែលមាននៅក្នុងសិទ្ធិការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលពុំត្រូវបានគោរពខ្ជាប់ខ្ជួនដោយតុលាការជាតិ សិទ្ធិទាំងនោះរួមមានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិក្នុងការទទួលបានការតំណាងផ្នែកច្បាប់ និងសិទ្ធិមិនត្រូវបានបង្ខំឲ្យសារភាព ឬដាក់ឲ្យជាប់ឃុំមុនសវនាការក្នុងរយៈពេលវែង ។ សូមមើលផងដែរ, មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម, ព្រឹត្តិប័ត្រឃ្លាំមើលតុលាការ, ភាគ៣, លេខ១៥ (ខែតុលា ឆ្នាំ២០០៦) ("ព្រឹត្តិប័ត្រឃ្លាំមើលតុលាការឆ្នាំ២០០៦") (ឯកសារចម្លងមាននៅជាមួយនឹង

តុលាការកម្ពុជា នៅពុំទាន់មានលក្ខណៈល្អឥតខ្ចោះក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែជាតុលាការដែលសាកសមបំផុតក្នុងការតម្រង់ផ្លូវប្រព័ន្ធតុលាការកម្ពុជា ។ នេះមិនមែនជាការនិយាយបំផ្លើសទេ ដែលវត្តមាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាបានឃើញពីរបៀបវិធីនៃដំណើរការរបស់តុលាការដែលអនុលោមតាមច្បាប់ ។ នីតិវិធីទាំងនោះរួមមានការទទួលបានសិទ្ធិក្នុងការបំភ្លឺនៅក្នុងតុលាការ ការមានសិទ្ធិអំណាចក្នុងការតវ៉ាយ៉ាងបើកចំហ និងយ៉ាងសកម្មពីសំណាក់មេធាវីការពារក្តីចំពោះការប្តឹងចោទប្រកាន់ ព្រមទាំងមានសិទ្ធិទាមទារឲ្យតុលាការបើកសវនាការដើម្បីស្តាប់អំណះអំណាងរបស់ខ្លួនថែមទៀតផង ។ ចំណែកឯសេចក្តីសម្រេចវិញ គឺត្រូវធ្វើឡើងដោយមានហេតុផលច្បាស់លាស់ និងមានការត្រួតពិនិត្យជាក់ស្តែង ។

សកម្មភាពរបស់តុលាការកម្ពុជា ក្នុងការធានាឲ្យមានការអនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយស្មើភាពគ្នាចំពោះមុខច្បាប់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នឹងត្រូវតែពឹងផ្អែកស្ទើរតែទាំងស្រុងលើរាជរដ្ឋាភិបាលកម្ពុជា ដោយសារតែរាជរដ្ឋាភិបាលបានគ្រប់គ្រងលើប្រព័ន្ធតុលាការយ៉ាងមានប្រសិទ្ធិភាព ។[១១] អត្ថបទនេះ នឹងផ្តល់នូវគំនិតមួយចំនួនដែលកម្ពុជាអាចចាប់យកឱកាសដ៏ប្រសើរដើម្បីទទួលបានផលវិជ្ជមានពីផ្លែផ្កានៃយុត្តិសាស្រ្ត និងការអនុវត្តនីតិវិធីនានារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីពង្រឹងសមត្ថភាពតុលាការកម្ពុជា ។

## ២) អំណះអំណាងគាំទ្រសេចក្តីសន្និដ្ឋានដែរថាយុត្តិសាស្រ្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចយកមកអនុវត្តបាននៅក្នុងប្រព័ន្ធតុលាការជាតិរបស់កម្ពុជា

---

*អ្នកនិពន្ធ), រកឃើញថា ពីខែមិថុនា ខែកញ្ញ ឆ្នាំ២០០៦ មានការរំលោភសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ នៅក្នុងតុលាការកម្ពុជា រួមបញ្ចូលទាំង សិទ្ធិក្នុងការសន្មតថាគ្មានទោស សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីក្នុងពេលមួយសមស្រប និងសិទ្ធិក្នុងការទទួលបានការជ្រោមជ្រែងពីមេធាវី ។*

[១១] *សូមមើល, អ្នករាយការណ៍ពិសេស, របាយការណ៍របស់អ្នករាយការណ៍ពិសេសពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, បញ្ជូនទៅមហាសន្និបាត, កិច្ចប្រជុំលើកទី១៥, ឯកសារអង្គការសហប្រជាជាតិ* A/HRC/15/46, *កថាខណ្ឌទី៤១ (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០) («របាយការណ៍របស់អ្នករាយការណ៍ពិសេសឆ្នាំ២០១០); របាយការណ៍របស់អ្នករាយការណ៍ពិសេសពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, ឯកសារអង្គការសហប្រជាជាតិ* A/HRC/18/46, *កថាខណ្ឌទី២៣ (ថ្ងៃទី២ ខែសីហា ឆ្នាំ២០១១) («របាយការណ៍ពិសេសឆ្នាំ២០១១) ។ សូមមើលផងដែរ, សេចក្តីប្រកាសព័ត៌មាន,* CCHR, *Blurred Separation of Powers Serves the Political Objectives of the Executive (ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១១) ( ឯកសារចម្លងមាននៅជាមួយនឹងអ្នកនិពន្ធ) ។*

## ២.១) តួនាទីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមជាតុលាការក្នុងស្រុក

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងក្នុងនាមជាតុលាការក្នុងស្រុក ។[១២] រាជរដ្ឋាភិបាលកម្ពុជាបានច្រានចោលនូវគំនិតដែលចង់ប្រែក្លាយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅជាតុលាការអន្តរជាតិ ដូចដែលសហគមន៍អន្តរជាតិបានស្នើឡើងនៅអំឡុងពេលនៃកិច្ចចរចារវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[១៣] គោលបំណងជាក់លាក់របស់រាជរដ្ឋាភិបាលកម្ពុជា គឺការបង្កើតតុលាការក្នុងស្រុកមួយដែលមានធាតុផ្សំជាអន្តរជាតិ ។ បើទោះបីជាត្រូវបានចាត់ទុកជាតុលាការ "អន្តរតូបនីយកម្ម" (ត្រូវបានចាត់ទុកជាតុលាការមួយដែលមានលក្ខណៈមិនច្បាស់លាស់) ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការមួយដែលបង្កប់នៅក្នុងប្រព័ន្ធតុលាការជាតិកម្ពុជា ។ គោលបំណងនេះបានស្តែងឲ្យឃើញនៅក្នុងឯកសារដែលមានចំណងជើងថា កិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានបង្កើត និងកំណត់នូវយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឯកសារទាំងពីរនេះយោងលើការបង្កើត "អង្គជំនុំជម្រះវិសាមញ្ញ" មួយដែលស្ថិតក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការដែលមានស្រាប់ ។

នៅអំឡុងពេលនៃកិច្ចចរចាដែលបានចំណាយពេលវេលាយ៉ាងយូរ មុនឈានឆ្ពោះទៅដល់ការចុះកិច្ចព្រមព្រៀង អង្គការសហប្រជាជាតិ បានសម្តែងពី "ការព្រួយបារម្ភអំពីបញ្ហាដែលពាក់ព័ន្ធនឹងនីតិរដ្ឋ និងដំណើរការនៃប្រព័ន្ធតុលាការ [នៅកម្ពុជា] ដែលបណ្តាលមកពីបញ្ហាមួយចំនួនដូចជា អំពើពុករលួយ និងការលូកដៃចូលក្នុងស្ថាប័នតុលាការពីសំណាក់ស្ថាប័ននីតិប្រតិបត្តិ ។"[១៤] អង្គការសហប្រជាជាតិបានស្នើឲ្យមានការផ្លាស់ប្តូរចំណុចមួយចំនួនលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀង ដែលចំណុចទាំងនោះរួមមានបទបញ្ញត្តិដែលទាមទារឲ្យមានចៅក្រមជាជនជាតិបរទេសភាគច្រើន នៅក្នុងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវធ្វើឡើងដោយមតិភាគច្រើន

---

១២ សូមមើល, សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច" 001/18-07-2007-ECCC/PTC, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងដីកាឃុំខ្លួនបណ្តោះអាសន្នចំពោះ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" កថាខណ្ឌទី១៩ (ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧) ("បណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងនឹងសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្ន") ។

១៣ អគ្គលេខាធិការ, របាយការណ៍របស់អគ្គលេខាធិការស្តីពីសាលាក្តីខ្មែរក្រហម, បញ្ជូនទៅមហាសន្និបាត, កិច្ចប្រជុំលើកទី ៥៧, ឯកសារអង្គការសហប្រជាជាតិ Doc. A/57/769, កថាខណ្ឌទី៦ (ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣) ។

១៤ ដូចខាងលើ ។ កថាខណ្ឌទី១៣ ។

ជាជាងការប្រើប្រាស់ “មតិភាគច្រើនដាច់ខាត” ហើយព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតគួរមានត្រឹមមួយរូបដែលមួយរូបនោះត្រូវតែជាភាគីអន្តរជាតិ (ជាជាងមានសហព្រះរាជអាជ្ញាពីររូប និងសហចៅក្រមស៊ើបអង្កេតចំនួនពីរនាក់ ដែលមានទាំងភាគីជាតិ និងភាគីអន្តរជាតិ ដូចមាននៅក្នុងច្បាប់ដើមនៃសេចក្តីព្រាង) ។[១៥] សំណើដើម្បីពង្រឹងសមត្ថកិច្ចខាងភាគីអន្តរជាតិនៅក្នុងតុលាការនេះ គឺដើម្បីជាការបង្ការ ចំពោះភាពទន់ខ្សោយនៃប្រព័ន្ធច្បាប់របស់កម្ពុជា ។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានមានប្រសាសន៍ថា សំណើឲ្យមានការផ្លាស់ប្តូរទាំងនោះ មានសារៈសំខាន់ក្នុងការ “ធានានូវអព្យាក្រឹតភាព ឯករាជភាព និងសុចរិតភាព និងលទ្ធភាពក្នុងការពិនិត្យមើលនីតិវិធីជម្រះក្តី ត្រូវបានការពារយ៉ាងពេញលេញ ។”[១៦] រាជរដ្ឋាភិបាលកម្ពុជាបានបដិសេធចំពោះសំណើសុំឲ្យមានការផ្លាស់ប្តូរនោះ ដោយបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនចង់ឲ្យមានតុលាការជាតិមួយ ដែលមិនមែនជាតុលាការអន្តរជាតិ និងមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយអន្តរជាតិ ។[១៧] ទោះបីជាមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិ ហើយយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជំនុំជម្រះលើបទឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ[១៨] ក៏វាបានបង្ហាញយ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបាន

---

[១៥] ដូចខាងលើ ។ កថាខណ្ឌទី១៦ ។

[១៦] ដូចខាងលើ ។

[១៧] អគ្គលេខាធិការអង្គការសហប្រជាជាតិបានមានប្រសាសន៍ថា “ខ្ញុំបានមើលឃើញយ៉ាងច្បាស់លាស់ នៅអំឡុងពេលនៃដំណើរទស្សនកិច្ចជាមួយក្រុមការងាររបស់ខ្ញុំទៅក្រុងភ្នំពេញ ដែលរាជរដ្ឋាភិបាលកម្ពុជាពុំបានត្រៀមខ្លួនរួចរាល់ក្នុងការពិនិត្យមើលយកចិត្តទុកដាក់លើសំណើ ដែលទាមទារឲ្យខ្លួនធ្វើការផ្លាស់ប្តូរលើបញ្ញត្តិមួយចំនួននៃច្បាប់ជាតិដែលមានបញ្ជាក់ច្បាស់លាស់ពីវិធីសាស្ត្រក្នុងការរៀបចំ និងបង្កើតជារចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញនៅឡើយ ។” ដូចខាងលើ។ កថាខណ្ឌទី២០ ។ ស្តីពីកិច្ចចរចាដែលឈានទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, *មើលទូទៅ,* Suzannah Linton, ដកស្រង់ចេញពីអត្ថបទ *Putting Cambodia's Extraordinary Chambers in Context,* 11 SING. Y.B. INT'L L. 195. 223-225 (2007) (“Linton ២០០៧”) ។

[១៨] ដូចដែលសាស្ត្រាចារ្យ Schabas បានកត់សម្គាល់ : “ដោយពិតទៅ តុលាការជាតិធ្វើការពាក់ព័ន្ធតែជាមួយឧក្រិដ្ឋកម្មអន្តរជាតិនោះ គឺពុំទាន់គ្រប់គ្រាន់សម្រាប់ធ្វើឲ្យតុលាការជាតិនោះក្លាយជាតុលាការអន្តរជាតិទេ.....ការសាកល្បងនោះ គួរតែពិនិត្យមើលថា តើសាលាក្តីនោះអាចនឹងត្រូវរំលាយដោយច្បាប់របស់ប្រទេសមួយបានដែរឬយ៉ាងណា ។ បើសិននេះជាករណីនៅកម្ពុជា នោះតុលាការជាតុលាការជាតិ ។ កម្ពុជាមានកិច្ចព្រមព្រៀងមួយជាមួយអង្គការសហប្រជាជាតិ ដោយសន្យាថា ខ្លួននឹងធ្វើកិច្ចសហប្រតិបត្តិការ ។ កិច្ចព្រមព្រៀងនោះទទួលបានការយល់ព្រមតាមរយៈសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ។ យ៉ាងណាក៏ដោយ ក្របខណ្ឌច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពិតជាក្របខណ្ឌជាតិ ។ អ្វីដែលអ្នកបង្កើតច្បាប់របស់កម្ពុជាអាចធ្វើបាន ក៏អាចស្រាយវិញបានដែរ ។” WILLIAM A.

បង្កើតឡើងក្នុងឋានៈជាតុលាការពិសេស (sui generis) ដែលស្ថិតនៅក្នុងប្រព័ន្ធតុលាការជាតិ ហើយចង់ភ្ជាប់កាតព្វកិច្ចដោយរដ្ឋធម្មនុញ្ញ និងច្បាប់កម្ពុជាដទៃទៀត ។[១៩] ផ្ទុយពីការរំពឹងទុក ចំណងស្ថាប័នដ៏រឹងមាំរវាងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការកម្ពុជា បានប្រែក្លាយនូវការរំពឹងទុកមួយដែលថា យុត្តិសាស្ត្រដែលចេញពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នឹងត្រូវយកទៅប្រើប្រាស់យ៉ាងយកចិត្តទុកដាក់ពីសំណាក់តុលាការជាតិ ទោះបីជាការពិតជាក់ស្តែង សេចក្តីសម្រេចរបស់

---

SCHABAS, ដកស្រង់ចេញពីអត្ថបទ UNIMAGINABLE ATROCITIES: JUSTICE, POLITICS, AND RIGHTS AT THE WAR CRIMES TRIBUNALS 19 (OUP 2012) ។

[១៩] បើទោះបីជាសេចក្តីសម្រេចមួយចំនួនរបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការ“អន្តរតូបនីយកម្ម” អ្នកនិពន្ធបានអះអាងថា ការកំណត់លក្ខណៈបែបនេះគ្រាន់តែជាការសន្មតតែប៉ុណ្ណោះ ហើយពុំមានមូលដ្ឋានគ្រឹះនៅក្នុងយុត្តិសាស្ត្រណាមួយឡើយ ។ បើទោះបីជាពាក្យ “អន្តរតូបនីយកម្ម” ត្រូវបានយកមកប្រើប្រាស់យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែមិនមែនជាតុលាការអន្តរជាតិ ។ លក្ខណៈដែលអង្គជំនុំជម្រះពឹងផ្អែកលើដើម្បីកំណត់លក្ខណៈថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការ“អន្តរតូបនីយកម្ម”នោះ ដោយសារអង្គចៅក្រមរបស់តុលាការនេះ មានបញ្ចូលគ្នារវាងចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិដែលធ្វើសម្បថដាច់ដោយឡែកពីចៅក្រមនៃតុលាការក្នុងស្រុក ។ សេចក្តីសម្រេចរបស់តុលាការនេះ មិនអាចត្រួតពិនិត្យដោយតុលាការដែលឋិតនៅក្រៅរចនាសម្ព័ន្ធរបស់ខ្លួនបានឡើយ ។ តុលាការនេះក៏ពុំមានយុត្តាធិការដើម្បីវិនិច្ឆ័យលើសកម្មភាពរបស់ស្ថាប័នដទៃផ្សេងទៀតដែរ ។ មើលរឿងក្តី នួន ជា ០០២/១៩-០៩-២០០៧-អវតក/កសចអ (អបរជ៧៥), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ២១៥-២១៦ (ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១) (“សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ”); សំណុំរឿងនួនជា០០២/១៩-០៩-២០០៧-អវតក/អជសត, សេចក្តីសម្រេចស្តីពីការជំទាស់បឋមលើវិធាន៨៩ របស់ អៀង សារី (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែង និងអនុគ្រោះទោស), កថាខណ្ឌ៣២ (ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១) ។ លក្ខណៈទាំងនេះ មិនបានផ្លាស់ប្តូរឋានៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាតុលាការមួយដែលបង្កប់នៅក្នុងប្រព័ន្ធតុលាការក្នុងស្រុកទេ ។ ដូចដែលអង្គជំនុំជម្រះ សាលាដំបូងបានទទួលស្គាល់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជា“ផ្នែកមួយនៃប្រព័ន្ធតុលាការកម្ពុជា” សំណុំរឿង នួន ជា., ០០២/១៩-០៩-២០០៧-អវតក/កសចអ (អបរជ០១), សេចក្តីសម្រេចជាសាធារណៈស្តីពីសំណើសុំបន្ទាន់របស់សហមេធាវីការពារក្តីចំពោះការប្តឹងជិតចិត្តចៅក្រម ណី ថុល ដោយកំពុងរង់ចាំការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងសំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/កសចអ (អបរជ ០១), សេចក្តីសម្រេចជាសាធារណៈស្តីពីសំណើសុំបន្ទាន់របស់សហមេធាវីការពារក្តីចំពោះការប្តឹងជិតចិត្តចៅក្រម ណី ថុល ដោយកំពុងរង់ចាំការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នក្នុងសំណុំរឿង នួន ជា , កថាខណ្ឌ៣០ (ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨) ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតនៅក្នុងរចនាសម្ព័ន្ធរបស់តុលាការកម្ពុជាដែលមានស្រាប់,” សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ០០១/១៨-០៧-២០០៧-អវតក/អសជ សេចក្តីសម្រេចលើសំណើសុំដោះលែង, កថាខណ្ឌទី១០ (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩) ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនបានបង្កើតជាច្បាប់ថ្មីដាក់លាក់ណាមួយសម្រាប់តុលាការជាតិក៏ដោយ ។

## ២.២. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញគឺជាច្បាប់«កំពូល»នៃប្រទេសកម្ពុជា[២០] ដែលគ្រប់គ្រងលើកិច្ចដំណើរការទាំងតុលាការជាតិ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ រដ្ឋធម្មនុញ្ញបានអនុម័តគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ ដោយបញ្ចូលបទដ្ឋាននៃគោលការណ៍ទាំងនោះចូលក្នុងប្រព័ន្ធច្បាប់ជាតិ ។ រដ្ឋធម្មនុញ្ញបានចែងថា «ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញា ដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិកុមារ និងសិទ្ធិនារី ។»[២១]

ព្រះរាជាណាចក្រកម្ពុជា បានអនុម័តអនុសញ្ញាស្តីពីសិទ្ធិមនុស្សសំខាន់ៗ[២២] ដែលរួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(ICCPR) ។[២៣] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ គឺជាលិខិតុបករណ៍អន្តរជាតិសំខាន់មួយដែលទទួលស្គាល់កាតព្វកិច្ចរបស់រដ្ឋ

---

[២០] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ០៩២/០០៣/២០០៧, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ («សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧»), អាចរកបាននៅគេហទំព័រ http://www.ccc.gov.kh/english/cont_dec_2007.php (ចូលមើលចុងក្រោយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២) ។

[២១] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា., សូមមើលកំណត់សម្គាល់ជើងទំព័រលេខ២, មាត្រា៣១ ។

[២២] មើលឧទាហរណ៍., កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, ៩៩៣ U.N.T.S ១៧១ (ចុះហត្ថលេខានៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០, ចូលជាធរមាននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២), អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត និងការបន្ទាបបន្ថោក ឬការដាក់ទោស, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤, ១៤៦៥ U.N.T.S ៨៥(ចូលជាធរមាននៅថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៥០), អនុសញ្ញាស្តីពីសិទ្ធិកុមារ, ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩, ១៥៧៧ U.N.T.S ៣ (ចូលជាធរមាននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២), អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់រើសអើងប្រឆាំងនឹងស្ត្រី, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩, ១២៤៩ U.N.T.S ១៣ (ចុះហត្ថលេខានៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ និងចូលជាធរមាននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២) ។ យោងតាមបណ្តុំទិន្នន័យស្តីពីសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ, កម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័ន ឬចូលជាសមាជិកលើសន្ធិសញ្ញា កតិកាសញ្ញា និងពិធីសារ ចំនួន៦៥ ។ សូមមើលគេហទំព័រស្តីពីបណ្តុំទិន្នន័យសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ, អាចរកបាននៅគេហទំព័រ http://treaties.un.org/pages/CNs.aspx (ចូលមើលចុងក្រោយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២) ។

[២៣] ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, ៩៩៩ U.N.T.S ១៧១ (ចុះហត្ថលេខានៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០ ចូលជាធរមាននៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២) ។

ក្រោមធម្មនុញ្ញនៃអង្គការប្រជាជាតិ ក្នុងការជំរុញឲ្យមាន "ការគោរពសិទ្ធិមនុស្ស និងសេរីភាព ។"[២៤] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងអំពី "សិទ្ធិស្មើគ្នា និងមិនអាចដកហូតបាន"[២៥] និងការធានាជាអប្បបរមាដែលអនុវត្តចំពោះបុគ្គលគ្រប់រូបទាក់ទងនឹងសិទ្ធិស៊ីវិលរបស់បុគ្គលម្នាក់ៗ និងសិទ្ធិក្នុងការចូលរួមក្នុងផ្នែកនយោបាយ ក្នុងនោះក៏រាប់បញ្ចូលទាំងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីស្មើភាពគ្នាមុខច្បាប់ដែរ ។ ចាប់តាំងពីកម្ពុជាបានផ្តល់សច្ចាប័ន និងដាក់បញ្ចូលលិខិតុបករណ៍ទាំងនោះចូលក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួនរួចមក[២៦] តុលាការជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែអនុវត្ត និងគោរពតាមបទបញ្ញត្តិស្តីពីសិទ្ធិមនុស្ស ដើម្បីលើកតម្កើងគោលការណ៍នីតិរដ្ឋ ។[២៧] ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការក្នុងស្រុក ដូច្នេះរាល់ច្បាប់ និងលិខិតុបករណ៍ទាំងឡាយដែលត្រូវបានអនុម័តឡើងដើម្បីបង្កើត និងរៀបចំគ្រប់គ្រង អង្គជំនុំជម្រះវិសាមញ្ញមួយនេះក៏ត្រូវស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ និងអនុលោមត្រូវតាមគោលការណ៍នៃការគោរពសិទ្ធិមនុស្សមានចែង

---

[២៤] ដូចខាងលើ ។ បុព្វកថា ។

[២៥] ដូចខាងលើ ។

[២៦] មាត្រា៣១(២) ដល់មាត្រា៥០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានឆ្លុះបញ្ចាំងពីសិទ្ធិមួយចំនួនដែលមាននៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងនេះ ក្នុងនោះរួមមាន សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា៣៨ មានដូចជា លក្ខខណ្ឌតម្រូវទាក់ទងនឹងការចោទប្រកាន់ ការចាប់ខ្លួន ឬការឃាត់ខ្លួននៃជនណាម្នាក់អាចធ្វើទៅបាន លុះត្រាណាតែស្របតាមបញ្ញត្តិច្បាប់; សិទ្ធិការពារខ្លួនតាមផ្លូវច្បាប់; ត្រូវចាត់ទុកថាជាមនុស្សគ្មានទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ; ហើយវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, សូមមើលកំណត់សម្គាល់ជើងទំព័រទី២ ។

[២៧] *សូមមើល,* Elinor Fry, *ដកស្រង់ចេញពីអត្ថបទ Between Show Trials and Sham Prosecutions: The Rome Statute's Potential Effect on Domestic Due Process Protections*, 23 CRIM. L. FORUM 35 *(២០១២) (បានលើកឡើងថា រដ្ឋដែលបានផ្តល់សច្ចាប័នដូចជាកម្ពុជា ត្រូវបានបង្ខំឲ្យពង្រឹងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលជាផ្នែកនៃកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងក្នុងលក្ខន្តិកទីក្រុងរ៉ូម តាមរយៈការយោងលើមាត្រាដែលពាក់ព័ន្ធនឹងគោលការណ៍បំពេញបន្ថែម និងគោលការណ៍គ្មានការកាត់ទោសពីរដងលើបទល្មើសតែមួយ ដើម្បីឲ្យការជំនុំជម្រះក្តីរបស់តុលាការក្នុងស្រុកស្របតាមបទដ្ឋានអន្តរជាតិទាក់ទងនឹងការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវ) ។ សូមមើល, លក្ខន្តិកទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ, បើកឲ្យមានការចុះហត្ថលេខា នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨, ២១៨៧* U.N.T.S *៩០, មាត្រា១៧, ២០(៣) ("លក្ខន្តិកៈទីក្រុងរ៉ូម"), កម្ពុជាបានចុះហត្ថលេខាលើលក្ខន្តិកទីក្រុងរ៉ូមនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០០ ហើយបានផ្តល់សច្ចាប័ននៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ។ សូមមើល* Coalition for the International Criminal Court, *អាចរកបាននៅគេហទំព័រ* http://www.iccnow.org/?mod=country&iduct=29 *(ចូលមើលចុងក្រោយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២) ។*

ក្នុងរដ្ឋធម្មនុញ្ញផងដែរ ។[២៨] ការបកស្រាយយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យស្របតាមរដ្ឋធម្មនុញ្ញ គឺតម្រូវឲ្យមានការការពារសិទ្ធិមនុស្ស ហើយការបកស្រាយដូច្នេះនឹងអាចផ្តល់ជាគំរូល្អមួយសម្រាប់តុលាការជាតិ ។

## ២.៣. ទំនាក់ទំនងនៃការអនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិនៅកម្ពុជា

ទំនាក់ទំនងនៃការអនុវត្តច្បាប់អន្តរជាតិដែលបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញ និងជាមួយនឹងច្បាប់ជាតិនៃព្រះរាជាណាចក្រកម្ពុជា បានគាំទ្រចំពោះសេចក្តីសន្និដ្ឋានដែលថា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺអាចអនុវត្តន៍បាននៅក្នុងតុលាការជាតិ ដោយសារតែច្បាប់អន្តរជាតិដែលបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញក៏ជាច្បាប់ជាតិដែរ ។ ព្រះរាជាណាចក្រកម្ពុជាប្រកាន់យកប្រព័ន្ធទ្វិកនិយម (ផ្ទុយទៅនឹងប្រព័ន្ធឯកនិយម) នៅក្នុងវិធីសាស្ត្រនៃការអនុវត្តន៍ច្បាប់អន្តរជាតិ នៅក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន ។[២៩] ខុសពីប្រព័ន្ធឯកនិយមដែលច្បាប់អន្តរជាតិដើរទន្ទឹមគ្នាជាមួយនឹងច្បាប់ជាតិ

---

[២៨] ឧទាហរណ៍, ក្រុមប្រឹក្សាធម្មនុញ្ញដែលមានសមាសភាព៩រូបជ្រើសតាំងដោយព្រះមហាក្សត្រ រដ្ឋសភា និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ទទួលភារកិច្ច "ដើម្បីការពារ និងគោរពតាមរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្រោយពីមានការត្រួតពិនិត្យរួចរាល់ពីព្រឹទ្ធសភា" *(មើលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,* មាត្រា ១៣៦-១៣៨) ដែលតម្រូវឲ្យពិនិត្យមើលថាតើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្របទៅតាមរដ្ឋធម្មនុញ្ញដែរឬយ៉ាងណា ។ សំណៅដើមនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលអនុម័តដោយព្រឹទ្ធសភានៅក្នុងឆ្នាំ២០០១ ត្រូវបានរកឃើញថាពុំស្របនឹងរដ្ឋធម្មនុញ្ញទេ ដោយសារច្បាប់នោះអនុញ្ញាតឲ្យមានទោសប្រហារជីវិត ។ មើលសេចក្តីសម្រេចក្រុមប្រឹក្សារដ្ឋធម្មនុញ្ញលេខ០៤០/០០២/២០០១ កបធ ច (ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១), *អាចរកបាននៅគេហទំព័រ* http://www.eccc.gov.kh/en/document/legal/cambodia (ចូលមើលលើកចុងក្រោយនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២) ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០១ ត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ដើម្បីបង្កើតច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០៤ ។

[២៩] អង្គបុរេជំនុំជម្រះបានបដិសេធមិនបញ្ចេញយោបល់ពាក់ព័ន្ធនឹងចរិតលក្ខណៈរបស់កម្ពុជាក្នុងឋានៈជាប្រទេសកាន់យកប្រព័ន្ធច្បាប់ទ្វិកនិយម ដូចដែល អៀង សារី និងនួន ជា បានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទេ លុះត្រាតែមានលើកឡើងបញ្ហានេះនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ ។ សំណុំរឿងនួន ជា, ០០២/១៩-០៩-២០០៧-អវតក-កសចអ (អបវជ ១៤៥ និង ១៤៦, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៩៨ (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១); *សំណុំរឿងនួន ជា,* ០០២/១៩-០៩-២០០៧-អវតក-កសចអ (អបវជ ៣៥, ៣៧, ៣៨, និង ៣៩), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៤៨ (ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១០) ។ រដ្ឋធម្មនុញ្ញមិនបានចែងច្បាស់លាស់ថា តើកម្ពុជាអនុវត្តវិធីសាស្ត្រឯក ឬទ្វិនិយមនោះទេ ។ ប៉ុន្តែ សាស្ត្រាចារ្យ Linto បានកត់សម្គាល់ថា, "តុលាការ[កម្ពុជា] បានបដិសេធមិនពិចារណាលើអំណះអំណាងដែលមិនពាក់ព័ន្ធនឹងច្បាប់

ហើយអាចអនុវត្តដោយស្មើភាពគ្នាដោយតុលាការ ប្រព័ន្ធទ្វិកនិយមបានចាត់ទុកច្បាប់អន្តរជាតិដាច់ដោយឡែកពីច្បាប់ជាតិ ហើយច្បាប់អន្តរជាតិអាចយកមកអនុវត្តបានតែក្នុងករណីច្បាប់នោះត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនោះ ឬតាមរយៈការអនុវត្តរបស់សភា ។[៣០] នៅក្នុងព្រះរាជាណាចក្រកម្ពុជា គោលការណ៍សិទ្ធិមនុស្សអន្តរជាតិត្រូវបានបញ្ចូលទៅក្នុងក្របខណ្ឌនៃច្បាប់ជាតិតាមរយៈរដ្ឋធម្មនុញ្ញ និងអាចអនុវត្តបាននៅក្នុងតុលាការជាតិបើពិនិត្យមើលជាលក្ខណៈទ្រឹស្តី ។[៣១]

ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលស្គាល់ថា ទោះបីជាច្បាប់មួយមិនបានរំលោភបំពានលើរដ្ឋធម្មនុញ្ញក៏ដោយ ក៏តុលាការត្រូវពិចារណាថាតើការអនុវត្តច្បាប់នៅក្នុងករណីជាក់លាក់ណាមួយអាចផ្ទុយទៅនឹងបញ្ញត្តិណាមួយនៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់កម្ពុជាដទៃទៀត ឬអនុសញ្ញាអន្តរជាតិនានាដែលកម្ពុជាបានទទួលស្គាល់ដែរឬយ៉ាងណា ។ នៅក្នុងករណីដែលបានរកឃើញថា ការធ្វើវិសោធនកម្មច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ[៣២] ស្របគ្នាទៅនឹងរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញបានកត់សម្គាល់ថា ចៅក្រមជំនុំ

---

ដែលផ្អែកទាំងស្រុងលើច្បាប់អន្តរជាតិ ឬរដ្ឋធម្មនុញ្ញ ។» Linton, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១៧*, ទំព័រ២០៣ ។ រាជរដ្ឋាភិបាល បានបង្ហាញពីការពេញចិត្តចំពោះការប្រើប្រាស់ប្រព័ន្ធទ្វិកនិយម ដូចដែលបានសំអាងនៅក្នុងរបាយការណ៍ដែលផ្ញើជូនគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ ដោយយោងទៅលើអនុសញ្ញាចំនួន៨ដែលកម្ពុជាបានផ្តល់សច្ចាប័ន នៅមិនទាន់បានយកមកសំអាងនៅតុលាការកម្ពុជា ឬអាជ្ញាធររដ្ឋបាលនោះឡើយ បើទោះបីជាអនុសញ្ញាទាំងនោះបានផ្តល់មូលដ្ឋានសម្រាប់អភិវឌ្ឍន៍ស្ថាប័ននីតិបញ្ញត្តិក៏ដោយ ។ ជាក់ស្តែងអនុសញ្ញាទាំងនោះមានជាប់ពាក់ព័ន្ធនឹងការសង្កេត និងការពារសិទ្ធិមនុស្ស...» គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍, *Seventh Periodic Reports of States Parties Due in 1996: Cambodia. 05/05/97*, U.N. Doc. CERD/C/292/Add.2, កថាខណ្ឌ១៩ (ថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧) ។

[៣០] សូមមើល, Gabriele Olivi, *ដកស្រង់ចេញពីអត្ថបទ The Role of International Courts in Prosecuting International Crimes: New Perspectives*, 18 SRI LANKA J. INT'L L. ទំព័រ៨៣, ៨៦-៨៧ (២០០៦) ។

[៣១] នៅពេលឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់ មិនអាចយកមកប្រើប្រាស់ដើម្បីដាក់ទណ្ឌកម្មដោយផ្ទាល់នៅក្នុងតុលាការជាតិរបស់កម្ពុជា ច្បាប់ទាំងនោះអាចអនុវត្តបានតាមរយៈដាក់ចូលមកក្នុងក្របខណ្ឌច្បាប់ជាតិដោយស្ថាប័ននីតិបញ្ញត្តិ ដូចមានរួចមកហើយ ពាក់ព័ន្ធនឹងការដាក់បញ្ចូលឧក្រិដ្ឋកម្មអន្តរជាតិចូលក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ *សូមមើល*, ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, (ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩) («ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា») បកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរដោយ ឈឿង ប៊ុនឡេង, មាត្រា ១៣៨, ១៨៨, ១៩៣ ។ សម្រាប់ការជជែកពិភាក្សាបន្ថែមពាក់ព័ន្ធនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងប្រព័ន្ធក្នុងស្រុកទូទៅ, សូមមើល WARD N. FERDINANDUSSE, DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS (T.M.C. Asser Press 2006) ។

[៣២] មាត្រា៨ ដែលត្រូវបានធ្វើវិសោធនកម្ម បានចែងថា ចៅក្រមមិនត្រូវពិចារណាលើស្ថានសម្រាលទោស ឬផ្អាក ឬបន្ថយទោស ឲ្យទាបជាងលក្ខណៈចាំបាច់ទាបបំផុតសម្រាប់បទល្មើសឧក្រិដ្ឋ ដែលត្រូវដាក់ទណ្ឌកម្មពីបទធ្វើពលកម្មដោយបង្ខំឡើយ ។

ជម្រះមិនគួរផ្អែកតែទៅលើមាត្រាដែលធ្វើវិសោធនកម្មសម្រាប់ធ្វើការចោទប្រកាន់តែប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវពឹងផ្អែកលើច្បាប់ផងដែរ ។ ពាក្យថា "ច្បាប់"[៣៣] សំដៅទៅលើច្បាប់ជាតិ រួមមាន រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងអស់ដែលបានចូលជាធរមាន និងច្បាប់អន្តរជាតិនានាដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ ។[៣៤] ដូច្នេះហើយ ទោះបីជាការពិតជាក់ស្តែង ច្បាប់អន្តរជាតិមិនបានត្រូវយកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការជាតិក៏ដោយ ក៏ចៅក្រមក្នុងស្រុក ដូចជាចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាដើម ត្រូវចង់ភ្ជាប់កាតព្វកិច្ចដោយរដ្ឋធម្មនុញ្ញក្នុងការពិចារណាលើអនុសញ្ញាស្តីពីសិទ្ធិមនុស្សអន្តរជាតិ និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយស្មើភាពគ្នាចំពោះមុខច្បាប់ នៅក្នុងការអនុវត្ត និងការបកស្រាយច្បាប់ជាតិ ។[៣៥]

ថ្វីបើមានតម្រូវការពីរដ្ឋធម្មនុញ្ញឲ្យធ្វើការពិចារណាលើលិខិតុបករណ៍ច្បាប់អន្តរជាតិ និងការការពារសិទ្ធិមនុស្សអន្តរជាតិក៏ដោយ ក៏គោលការណ៍ច្បាប់អន្តរជាតិទាំងនោះកម្រនឹងយកមកអនុវត្តនៅក្នុងករណីជាក់ស្តែងដោយតុលាការកម្ពុជាណាស់ ។ របាយការណ៍ដែលទើបនឹងផ្សព្វផ្សាយដោយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានលើកឡើងពីការព្រួយបារម្ភទាក់ទងនឹង ឯករាជភាព និងសមត្ថកិច្ចរបស់តុលាការ ។ អ្នករាយការណ៍រូបនោះបានកត់សម្គាល់ឃើញថា "ទោះបីជាមានការធានាដោយរដ្ឋធម្មនុញ្ញ និងការបង្កើតស្ថាប័នផ្សេងៗ ដើម្បីលើកកម្ពស់ និងធានាអំពីឯករាជភាពរបស់តុលាការក៏ដោយ ក៏ប្រព័ន្ធតុលាការនៅពុំទាន់ដំណើរការប្រកប

---

[៣៣] *សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧, សូមមើលកំណត់សម្គាល់ជើងទំព័រទី២០, ទំព័រ១ ។*

[៣៤] *ដូចខាងលើ ។*

[៣៥] *ស្រដៀងគ្នានេះដែល ប្រព័ន្ធយុត្តិធម៌នៃតុលាការកំពូលសហរដ្ឋអាមេរិក យកច្បាប់អន្តរជាតិមកធ្វើការសម្រេចចិត្តក្នុងការជំនុំជម្រះក្តី ។ ឧទាហរណ៍ នៅក្នុងការសម្រេចចិត្តថា ការដាក់ទោសអស់មួយជីវិតដោយគ្មានការដោះលែងចលើអនីតិជននៅក្នុងរឿងក្តីដែលមិនមែនជាបទឧក្រិដ្ឋ ជាការរំលោភទៅលើបំរាមដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ(វិសោធនកម្មលើកទី៨) របស់សហរដ្ឋអាមេរិក ដែលប្រឆាំងនឹងការដាក់ទណ្ឌកម្មព្រៃផ្សៃ និងមិនសមហេតុផល ។ សូមមើល រឿងក្តី* Graham v. *Florida,* 130 S. Ct. 2011/ 2033-34(2010)" *"សាលក្រមរបស់ប្រទេសនីមួយៗ និងសហគមន៍អន្តរជាតិ មិនមែនជាសេចក្តីសម្រេចដូចមាននៅក្នុងចែងនៅក្នុងរដ្ឋធម្មនុញ្ញដែលត្រូវបានធ្វើវិសោធនកម្មចំនួន៨លើកនោះទេ ។ ប៉ុន្តែ "បរិយាកាសនៃការយល់ឃើញជាអន្តរជាតិពាក់ព័ន្ធនឹងការទទួលយកការដាក់ទណ្ឌកម្មណាមួយ" ក៏មិនមែនមានន័យថាមិនជាប់ពាក់ព័ន្ធនោះដែរ ។"...តុលាការបានចាត់ទុកច្បាប់ និងការអនុវត្តរបស់ប្រទេសដទៃទៀត និងកិច្ចព្រមព្រៀងអន្តរជាតិ ថាជាប់ពាក់ព័ន្ធនឹងវិសោធនកម្មទី៨ មិនមែនដោយសារនិយាមទាំងនោះចងកាតព្វកិច្ច ឬត្រួតពិនិត្យនោះទេ ។ ប៉ុន្តែ ដោយសារសាលក្រមសម្រេចសេចក្តីរបស់ប្រទេសមួយចំនួនក្នុងពិភពលោក ជាពិសេសការអនុវត្តទាក់ទងនឹងការផ្តន្ទាទោស គឺពុំស្របគ្នានឹងគោលការណ៍ជាមូលដ្ឋាននៃក្រមសីលធម៌ ដែលជាគោលការណ៍មួយបង្ហាញពីការសម្រេចចិត្តរបស់តុលាការត្រូវតែមានសំអាងហេតុគ្រប់គ្រាន់ដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន" (សេចក្តីយោងត្រូវបានលុបចេញ) ។*

ដោយប្រសិទ្ធិភាព ឯករាជ្យ និងមិនលម្អៀង នៅឡើយ ។[៣៦] ផ្នែកដែលគួរឲ្យព្រួយបារម្ភខ្លាំងជាងគេនៅក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌជាតិនៅក្នុងតុលាការជាតិ មានរាប់បញ្ចូលទាំងការកំហិតនូវការលើកអំណះអំណាងនៅក្នុងសាលសវនាការ[៣៧] អវត្តមាននៃការវិភាគច្បាប់ឲ្យបានល្អិតល្អន់ ឬការបោះពុម្ពផ្សាយសេចក្ដីសម្រេចដែលមានសំអាងហេតុ[៣៨] អំពើពុករលួយ និងការជ្រៀតជ្រែកផ្នែកនយោបាយចូលក្នុងស្ថាប័នតុលាការ[៣៩] ការពឹងផ្អែកខ្លាំងលើចម្លើយសារភាពដែលបានមកពីការសួរចម្លើយរបស់ប៉ូលីសដែលជារឿយៗគឺធ្វើឡើងក្រោមការបង្ខិតបង្ខំ[៤០] ការដាក់ឲ្យស្ថិតនៅក្នុងមន្ទីរឃុំឃាំងក្នុងរយៈពេលយូរដោយពុំមានការចោទប្រកាន់[៤១] និងការខ្វះសេចក្ដីទុកចិត្តពីសំណាក់សាធារណជនដែលថា តុលាការអាចនឹងផ្ដល់យុត្តិធម៌ ដោយមិនមានភាពលម្អៀង ។[៤២]

ភាពអន់ថយទាំងនេះត្រូវបានលាតត្រដាងឡើង នៅក្នុងរឿងដ៏ចម្រូងចម្រាសពាក់ព័ន្ធនឹងការប្រកាសទោសជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ចេញដោយតុលាការក្រុងភ្នំពេញទៅលើលោក ម៉ម

[៣៦] របាយការណ៍អ្នករាយការណ៍ពិសេសឆ្នាំ២០១០, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១១*, កថាខណ្ឌ៣០ ។ Bates លើកឡើងពី«ការទទួលស្គាល់ដោយខ្លួនឯងពីសភាពទន់ខ្សោយ»នៃប្រព័ន្ធតុលាការនៃប្រទេសកម្ពុជា, ដោយយោងទៅលើបទសម្ភាសន៍រវាងអ្នកប្រឹក្សាយោបល់មួយរូបជាមួយលោកចៅក្រម និល ណុន ។ របាយការណ៍របស់ Bates, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៥*, ទំព័រ៥, ៥០-៥១ ។

[៣៧] របាយការណ៍អ្នករាយការណ៍ពិសេសឆ្នាំ២០១០, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១១*, កថាខណ្ឌ៤២ ។

[៣៨] *ដូចខាងលើ ។* ចៅក្រម និល ណុន បានត្អូញត្អែរថា ចៅក្រមកម្ពុជាពុំបានធ្វើការពន្យល់លើការទាញហេតុផលរបស់បានជាក់លាក់នោះឡើយ ហើយលោកក៏បានលើកឡើងថា នៅពេលអនាគត លោកនឹងពន្យល់ពីសេចក្ដីសម្រេចរបស់លោកដោយប្រុងប្រយ័ត្ន និងឲ្យតម្លៃលើ «វប្បធម៌នៃការផ្ដល់ហេតុផលពេញលេញ»របស់ចៅក្រមអន្តរជាតិនៃក្រុមប្រឹក្សាជំនុំជម្រះ ។ របាយការណ៍របស់ Bates, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៥*, ទំព័រ៥០, ដោយយោងទៅលើបទសម្ភាសន៍រវាងអ្នកប្រឹក្សាយោបល់មួយរូបជាមួយលោកចៅក្រម និល ណុន ។

[៣៩] របាយការណ៍អ្នករាយការណ៍ពិសេសឆ្នាំ២០១០, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១១*, កថាខណ្ឌ៤៤, ៥១-៥២; របាយការណ៍របស់ Bates, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៥*, ទំព័រ៥២-៦០ ។

[៤០] របាយការណ៍របស់អ្នករាយការណ៍ពិសេស, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១១*, កថាខណ្ឌ៥១ ។

[៤១] បញ្ហានេះត្រូវបានលើកឡើងដោយចៅក្រម និល ណុន ។ *សូមមើល*, របាយការណ៍របស់Bates, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៥*, ទំព័រ៥១, ដោយយោងទៅលើបទសម្ភាសន៍រវាងអ្នកប្រឹក្សាយោបល់មួយរូបជាមួយលោកចៅក្រម និល ណុន ។

[៤២] របាយការណ៍អ្នករាយការណ៍ពិសេសឆ្នាំ២០១០, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១១*, កថាខណ្ឌ៤២ ។

សូណាន់ដូ ដែលជាប្រធានវិទ្យុឯករាជ្យ ពីបទញុះញង់សកម្មភាពបះបោរនៅភូមិប្រម៉ា[៤៣] ខេត្តក្រចេះ ។ ការប្រកាសទោស ត្រូវបានដាក់ចេញរយៈពេលបីថ្ងៃកន្លះក្រោយពីការជំនុំជម្រះក្តី ដែលបានធ្វើឡើងក្នុងរយៈពេលពីរខែក្រោយពីដែលលោក ម៉ម សូណាន់ដូ ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ។ នៅអំឡុងពេលនៃការជំនុំជម្រះក្តី ព្រះរាជអាជ្ញាបានបង្ហាញភ័ស្តុតាងតិចតួចប៉ុណ្ណោះចំពោះការជាប់ពាក់ព័ន្ធគាត់នៅក្នុងសកម្មភាពបះបោរនៅក្នុងភូមិប្រមា[៤៤] ។ រឿងក្តីនេះត្រូវបានចាត់ទុកថាជា «រឿងក្តីមួយដែលជំនុំជម្រះក្រោមការជំរុញផ្នែកនយោបាយនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ»[៤៥] ហើយក្រុមអ្នកការពារសិទ្ធិមនុស្សបានអះអាងថា រដ្ឋាភិបាលបានប្រឌិតរឿងដើម្បីបិទមាត់ប្រធានស្ថានីយវិទ្យុឯករាជ្យនៅកម្ពុជា និងដើម្បីបិទបាំងករណីជម្លៀសអ្នកភូមិប្រមាចំនួន៦០០នាក់ពាក់ព័ន្ធនឹងជម្លោះដីធ្លីជាមួយនឹងក្រុមហ៊ុនអាជីវកម្មកៅស៊ូមួយ ។[៤៦] អ្នកនាំពាក្យនៃស្ថានទូតអាមេរិក វិចតូរៀ នូលែន (Victoria Nuland) បានស្នើឲ្យរដ្ឋាភិបាល «ដោះលែងលោក ម៉ម សូណាន់ដូ ភ្លាមៗ

---

[៤៣] សំណុំរឿងព្រហ្មទណ្ឌលេខ២០៦ ចុះនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១២ នៃស្ថាប័នអយ្យការអមសាលាដំបូងខេត្តក្រចេះ និងបន្ទាប់មកសំណុំរឿងនេះត្រូវបានផ្ទេរមកស្ថាប័នអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលមានលេខសំណុំរឿង ២២០៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២ ។

[៤៤] នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ក្នុងពេល២ថ្ងៃក្រោយពីនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសឈ្មោះលោក ម៉ម សូណាន់ដូ ជាសាធារណៈ ចៅក្រមស៊ើបអង្កេតនៃសាលាដំបូងខេត្តក្រចេះ បានសម្រេចចិត្តពង្រីកការស៊ើបអង្កេតលើសំណុំរឿងក្តីព្រហ្មទណ្ឌលេខ២០៦ ដោយបញ្ចូលលោក ម៉ម សូណាន់ដូ ក្នុងសំណុំរឿងនេះ (ដីកាលេខ១៣៧/៣, ចេញនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ដោយចៅក្រមស៊ើបអង្កេតនៃសាលាដំបូងខេត្តក្រចេះ) ។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ លោក ម៉ម សូណាន់ដូ បានទទួលដីកាកោះអញ្ជើញដើម្បីសួរនាំ ប៉ុន្តែនៅពេលនោះគាត់មិនស្ថិតនៅក្នុងប្រទេស ។ ដីកាចាប់ខ្លួនក៏ត្រូវបានចេញនៅថ្ងៃដដែល ។ ម៉ម សូណាន់ដូ ត្រូវបានចាប់ខ្លួននៅភ្នំពេញនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១២ ។ សាលាដំបូងខេត្តក្រចេះបានផ្ទេរសំណុំរឿងនេះទៅឲ្យស្ថាប័នអយ្យអមសាលាដំបូងរាជធានីភ្នំពេញ ហើយបន្ទាប់មកសំណុំរឿងព្រហ្មទណ្ឌនេះត្រូវបានប្តូរមកសំណុំរឿងលេខ២២០៧ ។ ការស៊ើបអង្កេតបានបិទបញ្ចប់នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ ។ លោក ម៉ម សូណាន់ដូ ត្រូវបានចោទប្រកាន់ចំពោះបទល្មើសមួយចំនួនដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ដូចជា: ញុះញង់ឲ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ (មាត្រា ២៩ និងមាត្រា ៥០៤); ធ្វើការបះបោរ (មាត្រា ២៩, ៤៥៦ និងមាត្រា ៤៥៧); ការរំខានក្នុងការបំពេញមុខងារសាធារណៈ (មាត្រា៤៦៤ និងមាត្រា២៩) ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, សូមមើលកំណត់សម្គាល់ជើងទំព័រទី៣១ ។ ការជំនុំជម្រះក្តីត្រូវបានធ្វើឡើងនៅថ្ងៃទី១១ ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ ។ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១២, តុលាការបានប្រកាសសាលក្រម ។

[៤៥] Peter Zsombor, ដកស្រង់ចេញពីអត្ថបទ *Sonando Verdict a Tough Test for KRT Legacy,* នៅក្នុងកាសែត CAMBODIA DAILY, ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២, នៅទំព័រទី ១ ។

[៤៦] Peter Zsombor, ដកស្រង់ចេញពីអត្ថបទ *Donors Criticize Sonando Sentence,* នៅក្នុងកាសែត CAMBODIA DAILY, ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២, នៅទំព័រទី ២០ ។

ដើម្បីធានាថា ប្រព័ន្ធតុលាការនៅកម្ពុជា គឺមិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយ និងធ្វើការអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធានាចំពោះសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ។[៤៧] យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយស្មើភាពគ្នានៅមុខច្បាប់ នឹងក្លាយជាឧបករណ៍មួយសម្រាប់ចៅក្រមបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាំងអស់នេះ ។

## ៣.៤. លិខិតុបករណ៍គ្រប់គ្រងលើការអនុវត្ត និងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

លិខិតតុបករណ៍ដែលគ្រប់គ្រងលើការអនុវត្ត និងកិច្ចដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែគោរពតាមគោលការណ៍ជំនុំជម្រះក្តីដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ និងវិធាននៃនីតិវិធី ប៉ុន្តែវិធានស្តីពីនីតិវិធីនោះគួរតែធ្វើឡើងនៅកម្រិតអន្តរជាតិ ពីព្រោះវាជាទីដែលគេអាចមើលឃើញអំពីចន្លោះប្រហោងនៃច្បាប់របស់កម្ពុជា ។ ទំនាក់ទំនងរវាងការអនុវត្តច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ បានឆ្លុះបញ្ចាំងអំពីការតម្រូវឲ្យច្បាប់ជាតិត្រូវតែស្របទៅនឹងគោលការណ៍ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលបានដាក់បញ្ចូលបញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងលិខិតតុបករណ៍សិទ្ធិមនុស្សមួយចំនួនទៀត ។

### ៣.៤.១. កិច្ចព្រមព្រៀង

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានចុះកិច្ចព្រមព្រៀងដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាផ្លូវការ ក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ព្រមទាំងផ្តល់មូលដ្ឋានច្បាប់ គោលការណ៍ និងគំរូសម្រាប់កិច្ចសហប្រតិបត្តិការ ។ យោងតាមមាត្រា១២ នៃកិច្ចព្រមព្រៀងនេះ នីតិវិធីដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាត្រូវតែ“ស្របតាមច្បាប់របស់កម្ពុជា” ។ ប៉ុន្តែ កិច្ចព្រមព្រៀងដដែលនេះក៏បានចែងដែរថា “សេចក្តី

---

[៤៧] ដូចខាងលើ ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទើបបានសម្តែងពីក្តីព្រួយបារម្ភពី “ការជ្រៀតជ្រែកនយោបាយដោយគ្មានការលាក់លៀម” ដែលនាំឲ្យតុលាការខេត្តមួយនៅកម្ពុជាសម្រេចចិត្តបិទបញ្ឈប់ការស៊ើបអង្កេតក្នុងរឿងក្តីសម្លាប់សកម្មជនការពារបរិស្ថានដ៏មានកេរ្តិ៍ឈ្មោះល្បី, លោក ឈុត វុទ្ធី នៅពេលដែលលោកបាននាំអ្នកកាសែតចុះទៅធ្វើការស៊ើបអង្កេតក្នុងសំណុំរឿងកាប់ព្រៃឈើខុសច្បាប់ ។ សេចក្តីប្រកាសព័ត៌មាន, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានលើកឡើងថា ការបញ្ឈប់ការស៊ើបអង្កេតចំពោះរឿងក្តីរបស់លោក ឈុត វុទ្ធី គឺជាការបង្ហាញឲ្យឃើញពីការជ្រៀតជ្រែកផ្នែកនយោបាយ (ថ្ងៃទី៧ ខែតុលា ឆ្នាំ២០១២) (ឯកសារនេះនៅជាមួយនឹងអ្នកនិពន្ធ) ។

ណែនាំគួរតែត្រូវបានដាក់បញ្ចូលនូវវិធានផ្សេងៗទាក់ទងនឹងនីតិវិធីដែលបានបង្កើតនៅថ្នាក់អន្តរជាតិ» នៅពេលមានចំណុចខ្វះខាត និងភាពមិនច្បាស់លាស់ ឬមួយនៅពេលដែលច្បាប់កម្ពុជាមិនស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ ។[៤៨]

មាត្រា ១២(២) បានចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ត្រូវតែអនុវត្តយុត្តាធិការរបស់ខ្លួនឲ្យស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពមិនលម្អៀង និងការគោរពតាមកិច្ចដំណើរការនីតិវិធីនៃច្បាប់ ដូចដែលបានចែងនៅក្នុងមាត្រា១៤ និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ មាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានចែងអំពីសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ចំពោះជនគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។ សិទ្ធិទាំងនោះរួមមាន៖ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយភាពត្រឹមត្រូវ និងជាសាធារណៈ ដោយអង្គជំនុំជម្រះមួយដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង, សិទ្ធិដែលទទួលបានការសន្មតថាជាជនគ្មានទោសដរាបណាពុំទាន់រកឃើញថាមានទោស, សិទ្ធិក្នុងការទទួលបានព័ត៌មានអំពីការចោទប្រកាន់, សិទ្ធិទទួលបានពេលវេលា និងធនធានគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវី, សិទ្ធិទទួលបានការជំនុំជម្រះដោយពុំមានការពន្យារពេល និងសិទ្ធិទទួលបានការជម្រះក្តីនៅចំពោះមុខ ។ មាត្រា១៥ បានចែងអំពីគោលការណ៍ធម្មានុរូប ថា «ពុំមានជនណាម្នាក់ត្រូវបានដាក់ឲ្យជាប់ពិរុទ្ធក្នុងបទល្មើសព្រហ្មទណ្ឌ នៅពេលដែលអំពើនោះមិនត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ ដែលស្ថិតនៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ខណៈពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើងនោះឡើយ ។»

### ២.៤.២. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើង «ដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតលើបទឧក្រិដ្ឋ និងការរំលោភបំពានធ្ងន់ធ្ងរលើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា»[៤៩] ច្បាប់មនុស្ស

[៤៨] កិច្ចព្រមព្រៀង, សូមមើលកំណត់សម្គាល់ជើងទំព័រទី៤, មាត្រា ១២(១) ។

[៤៩] បើទោះបីជាមានការរំពឹងទុកថាជនជាប់ចោទដែលបង្ហាញមុខនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងទទួលបានសច្ចធារណ៍នៃនិរទោសនៅក្នុងដំណាក់កាលជម្រះក្តីក៏ពិតមែន (សូមមើល រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, សូមមើលកំណត់សម្គាល់ជើងទំព័រទី២, មាត្រា៣៨, ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, សូមមើលកំណត់សម្គាល់ជើងទំព័រទី៣, មាត្រា៣៥ថ្មី) , ក៏វាជារឿងមួយដែលគួរឲ្យខកចិត្ត ដោយឯកសារបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានប្រើភាសាដែលពាក់ព័ន្ធនឹងសច្ចធារណ៍នៃពិរុទ្ធភាព ។

ធម៌ និងទំនៀមទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ ។»[៥០] សំណៅដើមនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០១ (មុនចុះហត្ថលេខាលើកិច្ចព្រមព្រៀងឆ្នាំ២០០៣) និងត្រូវបានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០០៤ ។ ស្របពេលនឹងគោលបំណងនៃកិច្ចព្រមព្រៀងត្រូវបានតាក់តែងឡើងដើម្បីបង្កើតកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាតួនាទីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញកម្ពុជាត្រូវបានដាក់ឲ្យអនុវត្តជាក់ស្តែងដើម្បីដឹងអំពីរបៀបនៃដំណើរប្រព្រឹត្តទៅ ក៏មានដែរការកំណត់កម្មវត្ថុជាក់លាក់ទាក់ទងនឹងយុត្តាធិការលើបុគ្គល និងយុត្តាធិការពេលវេលា ។ និយាយដោយសាមញ្ញកិច្ចព្រមព្រៀងនោះ ត្រូវតែអនុវត្តតាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[៥១] ប្រសិនបើក្រឡេកមើលលើមាត្រា១២(២) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ជាក់ដែរថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែអនុវត្តយុត្តាធិការរបស់ខ្លួនដោយយោងតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការអនុវត្តត្រឹមត្រូវតាមច្បាប់ដូចដែលមានចែងនៅមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ ។

បើទោះបីជាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអនុម័តឡើងដើម្បីប្រើសម្រាប់តែនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមិនអាចអនុវត្តផ្ទាល់នៅក្នុងតុលាការដទៃទៀតក៏ពិតមែន តែវាគឺជាមូលដ្ឋានគ្រឹះមួយនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដែលបានប្រើប្រាស់គោលការណ៍អន្តរជាតិទាក់ទងនឹងការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ដោយរាប់បញ្ចូលទាំង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ តុលាការកម្ពុជាមានកាតព្វកិច្ចត្រូវពិចារណាលើបទដ្ឋានអន្តរជាតិនានាដែលត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ នៅពេលមានការអនុវត្តទាក់ទងនឹងច្បាប់ជាតិ មានន័យថា យុត្តិសាស្ត្រនៃការអនុវត្តច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចជាសេចក្តីណែនាំសម្រាប់តុលាការជាតិក្នុងការបកស្រាយបញ្ញត្តិស្រដៀងគ្នានេះ ។ ជាឧទាហរណ៍ក្រមព្រហ្មទណ្ឌដែលទើបនឹងត្រូវបានអនុម័តនាពេលកន្លងទៅថ្មីៗនេះ ដែលបានដាក់បញ្ចូលបទឧក្រិដ្ឋកម្មអន្តរជាតិទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពាន

---

[៥០] ច្បាប់ស្តីពីការបង្កើត, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៣*, មាត្រា១ ។

[៥១] កិច្ចព្រមព្រៀង, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៣*, មាត្រា១២(២) (បានចែងថា «កិចព្រមព្រៀងនាពេលបច្ចុប្បន្នត្រូវតែអនុវត្តនៅកម្ពុជាតាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចដែលបានអនុម័ត និងធ្វើវិសោធនកម្ម») ។

យ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[៥២] ដែលអាចនឹងត្រូវជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា[៥៣] បានបង្ហាញឲ្យឃើញថា ផលដែលកើតចេញពីយុត្តិសាស្ត្រ និងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងផ្តល់ឱកាសសម្រាប់តុលាការកម្ពុជាដើម្បីអនុវត្តយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ២.៤.៣. វិធានផ្ទៃក្នុង

វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានអនុម័តនៅក្នុងខែមិថុនា ឆ្នាំ២០០៧[៥៤] ដោយកិច្ចប្រជុំពេញអង្គនៃចៅក្រមជាតិ និងអន្តរជាតិ ។ ដូចដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ វិធានផ្ទៃក្នុង «បានបង្កើតនូវរបបឯករាជ្យនៃច្បាប់នីតិវិធីមួយដែលពាក់ព័ន្ធនឹងកាលៈទេសៈជាក់លាក់របស់អង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា ។[៥៥] ទោះបីជា វិធានផ្ទៃក្នុងមិនបានចែងផ្ទុយពីអ្វីដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ («ក្រមនីតិវិធីព្រហ្មទណ្ឌ») ក៏អង្គបុរេជំនុំជម្រះបានយល់ថា វិធានផ្ទៃក្នុងគួរតែត្រូវបានចាត់ទុកថាជា «ឯកសារបឋម»[៥៦] សម្រាប់យកមកសំអាងនៅក្នុងករណីដែលមានភាពខុសគ្នារវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធី

[៥២] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៣១*, មាត្រា១៨៣, ១៨៨, ១៩៣ ។

[៥៣] ច្បាប់ស្តីពីការបង្កើត, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៣, មាត្រា ៤, ៥, ៦ ។*

[៥៤] *វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មពីរដងជារៀងរាល់ឆ្នាំ ពីខែកុម្ភៈ ឆ្នាំ២០០៨ រហូតដល់វិសោធនកម្មចុងក្រោយ (សេចក្តីពិនិត្យឡើងវិញលើកទី៨)*, អនុម័តនៅខែសីហា ឆ្នាំ២០១១ ។

[៥៥] *សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧៤-អវតក/កសចស)(អបរជ០៦), សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធសំណើសុំមោឃភាព»), កថាខណ្ឌ១៤ (ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨) («សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធសំណើសុំមោឃភាព») ។*

[៥៦] *ដូចខាងលើ ។ អង្គជំនុំជម្រះសាលាដំបូងក៏បានគាំទ្រការយល់ឃើញនេះដែរ ។ សូមមើលសំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសត, សេចក្តីសម្រេចលើសេចក្តីជំទាស់បឋមរបស់ នួន ជា ក្នុងអះអាងស្តីពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, កថាខណ្ឌ៧៨ (ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១) ។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រចំពោះវិធីសាស្ត្រខុសគ្នាមួយដែលប្រកាន់យកថា «ច្បាប់កម្ពុជានៅតែអាចប្រើប្រាស់ដើម្បីគ្រប់គ្រងនីតិវិធីនៅក្នុងសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជួយបំពេញកន្លែងដែលច្បាប់នោះមានកង្វះខាតមិនគ្រប់លក្ខខណ្ឌតម្រូវជាក់លាក់នៅក្នុងបទបញ្ញត្តិទាំងនោះ ។» សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ «ឌុច» ០០១/១៨-០៧-២០០៧-អវតក/អជតក, សាលក្រមតុលាការកំពូល, កថាខណ្ឌ៤០៩ (ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២) («សាលក្រមតុលាការកំពូលក្នុងសំណុំរឿង ឌុច») ។*

ព្រហ្មទណ្ឌ ។ បន្ថែមពីលើនេះ បទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ គួរត្រូវលើកយកមកប្រើតែនៅក្នុងករណីដែលវិធានផ្ទៃក្នុងពុំអាចដោះស្រាយបានតែប៉ុណ្ណោះ ។[៥៧]

រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិអំណាចគតិយុត្តិដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីអនុម័តវិធានផ្ទៃក្នុងតាមរយៈមាត្រា៣៣ថ្មីនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប៉ុន្តែ សិទ្ធិអំណាចក្នុងការអនុម័តវិធានផ្ទៃក្នុងនេះ អាចធ្វើបានតែក្នុងករណីដែលនីតិវិធីដែលមានស្រាប់ «ពុំអាចដោះស្រាយបញ្ហាជាក់លាក់ណាមួយ ឬមួយក្នុងករណីដែលមានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការបកស្រាយ ឬមួយទាក់ទងនឹងការអនុវត្ត ឬក៏មានសំណួរពាក់ព័ន្ធនឹងភាពស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិតែប៉ុណ្ណោះ» ។[៥៨] ការអនុវត្តទាក់ទងនឹងការបង្កើតវិធានស្តីពីនីតិវិធីដែលផ្តោតលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានភាពស្របគ្នាទៅនឹងនីតិវិធីដែលបានប្រើប្រាស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលហៅកាត់ថា (ICC) និងអង្គជំនុំជម្រះពិសេសមួយចំនួនទៀតដែលលក្ខន្តិកដើម្បីគ្រប់គ្រងអង្គជំនុំជម្រះទាំងអស់នោះ អនុញ្ញាតឲ្យមានការអនុម័តវិធានស្តីពីនីតិវិធីជាក់លាក់មួយបាន ដោយពុំមានការកំហិតដូចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានកំណត់ថា វិធានបែបនេះអាចនឹងត្រូវបានបង្កើតឡើងតែក្នុងករណីមានចន្លោះប្រហោងនៅក្នុងច្បាប់ក្នុងស្រុកតែប៉ុណ្ណោះ ។[៥៩]

---

[៥៧] សេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបដិសេធសំណើសុំមោឃភាព, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៥៥*, កថាខណ្ឌ១៥ ។

[៥៨] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៣*, មាត្រា៣៣ ។

[៥៩] *សូមមើល*, លក្ខន្តិកទីក្រុងរ៉ូម, *កំណត់សម្គាល់ជើងទំព័រទី២៧*, មាត្រា៥១, ដែលបានចែងពី «វិធានស្តីពីនីតិវិធី និងភស្តុតាង» ដែលត្រូវបានអនុម័តដោយសំឡេងពីរភាគបីនៃមតិភាគច្រើនដោយសមាជិកនៃសមជិកសភានៃរដ្ឋជាភាគី ។ វិធាននានា និងការវិសោធនកម្ម ត្រូវតែស្របគ្នាទៅនឹងលក្ខន្តិកទីក្រុងរ៉ូម ។ *សូមមើល* លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី, U.N. Doc. S/RES/827, មាត្រា១៥ (ទី២៥ ខែឧសភា ឆ្នាំ១៩៩៣) ដែលទាមទារឲ្យចៅក្រមអនុម័ត «វិធានស្តីពីនីតិវិធី និងភស្តុតាងសម្រាប់ដំណាក់កាលកិច្ចដំណើរការនីតិវិធីមុនសវនាការ, អង្គជំនុំជម្រះ និងដំណាក់កាលបណ្តឹងឧទ្ធរណ៍, ដំណាក់កាលនៃការដាក់ភស្តុតាង, ការការពារជនរងគ្រោះ និងសាក្សី និងបញ្ហាដទៃទៀត ។» បញ្ញត្តិនេះឆ្លុះបញ្ចាំងនៅក្នុងលក្ខន្តិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា, U.N. Doc. S/Res/955, មាត្រា១៤ (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤) ដែលបានចែងពីវិធានពាក់ព័ន្ធនឹង «បញ្ហាសមស្របដទៃទៀតនៃតុលាការអន្តរជាតិសម្រាប់អាតីតយូហ្គោស្លាវីជាមួយនឹងការចោទប្រកាន់ដែលពួកគេចាត់ទុកថាមានសារៈសំខាន់» ។ស្ថាប័ននីមួយៗ បានអនុម័តវិធានស្តីពីនីតិវិធីដែលស្របតាមបទបញ្ញត្តិទាំងនោះ ។

ផ្ទុយពីមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការអះអាងមួយបានលើកឡើងថា ក្របខណ្ឌគតិយុត្តិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពុំបានផ្តល់អំណាចឲ្យចៅក្រមដើម្បីតាក់តែងវិធានស្តីពីបញ្ហានីតិវិធីនោះទេ ដោយសារវិធានដែលអនុម័តដោយចៅក្រមអាចនឹងប៉ះពាល់ ឬផ្ទុយពីវិធានដែលអនុម័តដោយរដ្ឋសភាជាតិ ។ វិធីអនុវត្តន៍ល្អជាងនេះអាចធ្វើឡើងដោយការអនុម័តសេចក្តីប្រកាសបកស្រាយនៃមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ តាមរយៈកិច្ចប្រជុំពេញអង្គ ដោយការកំណត់នូវផ្សំនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជាមួយណា ដែលមានភាពច្បាស់លាស់ និងស្របទៅតាមបទដ្ឋានអន្តរជាតិ និងធាតុផ្សំមួយណាមិនច្បាស់លាស់ និងមិនស្របទៅតាមបទដ្ឋានអន្តរជាតិ ដូចដែលអ្នកស្រាវជ្រាវច្បាប់មួយរូបបានធ្វើការកត់សម្គាល់ ។[៦០] ការអនុវត្តបែបនេះអាចបង្ហាញឲ្យឃើញច្បាស់ពីវិធីសាស្ត្រដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំណត់ថាតើវិធានស្តីពីនីតិវិធីព្រហ្មទណ្ឌអន្តរជាតិណាមួយ ដែលគួរតែដើរតួនាទីក្នុងការ "ការបំពេញចន្លោះ" ឬជា "មានតួនាទីកែលំអ" ដូចដែលមានចែងនៅក្នុងមាត្រា១២(១) នៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។[៦១] ប៉ុន្តែ ថ្វីបើមានវិធីសាស្ត្រច្បាស់លាស់ សម្រាប់ដោះស្រាយលើបញ្ហាចន្លោះប្រហោង ឬភាពមិនច្បាស់លាស់យ៉ាងណាក្តី ក៏អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ចៅក្រមនៃកិច្ចប្រជុំពេញអង្គអនុវត្តន៍តែសកម្មភាពដែលស្ថិតនៅក្នុងវង្វង់អំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការធ្វើសេចក្តីព្រាង និងអនុម័តវិធានផ្ទៃក្នុង[៦២] តែប៉ុណ្ណោះ ។[៦៣] ជាការពិត ការអនុញ្ញាតឲ្យចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬអង្គជំនុំជម្រះអន្តរជាតិដទៃទៀតមានលទ្ធភាពដោយសេរីក្នុងការបង្កើតវិធានស្តីពីនីតិវិធី រួចហើយប្រកាសថាការបង្កើតវិធានទាំងនោះស្ថិតនៅក្រោមអំណាចឆន្ទានុសិទ្ធិដ៏ទូលំទូលាយចៅក្រមទាំងអស់នោះ គឺបង្ហាញឲ្យឃើញពីគ្រោះថ្នាក់ នៅពេលដែលវិធានស្តីពីនីតិវិធីត្រូវបានបង្កើតឡើងដោយចៅក្រមដើម្បីពន្លឿនការជំនុំជម្រះ និងដើម្បីសន្សំសំចៃធនធាន ពិតជានឹងប៉ះពាល់ដល់សិទ្ធិសំខាន់ៗដោយជៀសមិនរួច ។

---

[៦០] Goran Sluiter, *ដកស្រង់ចេញពីអត្ថបទ Due Process and Criminal Procedure in the Cambodian Extraordinary Chambers*, 4:2 J. INT'L CRIM. JUST. 314, 320 (2006) ។

[៦១] *ដូចខាងលើ ។*

[៦២] *សូមមើល, សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសត, សេចក្តីសម្រេចលើសេចក្តីជំទាស់បឋមរបស់ នួន ជា ក្នុងអះអាងស្តីពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, កថាខណ្ឌ៩ (ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១) ។*

[៦៣] *វិធានផ្ទៃក្នុងត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំដោយសារតែដំណើរការមាន "ភាពមិនច្បាស់លាស់", របាយការណ៍របស់* Bates, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៥, ទំព័រ៤៧ ។*

បើទោះបីជា វិធានផ្ទៃក្នុងអាចអនុវត្តផ្តោតជាសំខាន់សម្រាប់តែការអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ដោយ ប៉ុន្តែស្ទើរតែគ្រប់ផ្នែកនៃវិធានផ្ទៃក្នុង ពឹងផ្អែកលើ និងមានមូលដ្ឋានគ្រឹះចេញពីនីតិវិធីរបស់កម្ពុជា ។ វិធានផ្ទៃក្នុងបំពេញបន្ថែមលើគោលការណ៍នៃនីតិវិធីក្នុងស្រុក ដោយដាក់បញ្ចូលនូវសិទ្ធិស្តីពីការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ បទដ្ឋានអន្តរជាតិនានា និងគោលការណ៍អន្តរជាតិ ដែលមានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ដែលតុលាការកម្ពុជាទាំងអស់ត្រូវអនុវត្តន៍ ។ ហេតុដូច្នេះហើយ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលធ្វើឡើងដោយអនុលោមតាមវិធានផ្ទៃក្នុង គួរតែត្រូវបានយកទៅពិចារណា និងអនុវត្តដោយតុលាការក្នុងស្រុកនៅក្នុងពេលសមស្របណាមួយ ។ វិធានផ្ទៃក្នុង មិនអាច និងមិនគួរជំនួសនីតិវិធីកម្ពុជានោះទេ ដោយសារតែគោលការណ៍ទាំងនោះមានលក្ខណៈស្របគ្នាទៅនឹងគោលការណ៍អន្តរជាតិ ។ វិធីសាស្ត្របៀបនេះនឹងជួយពីអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា ក្នុងការអនុម័តបទបញ្ជាផ្ទៃក្នុង និងធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពនៃតុលាការនេះដើម្បីបន្សល់ទុកនូវកេរដំណែលយុត្តិសាស្ត្រនៃការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ដែលអាចយកទៅអនុវត្តន៍បាននៅក្នុងតុលាការជាតិ ។

### ២.៤.៤. យុត្តិសាស្ត្រនៃតុលាការអន្តរជាតិ និងតុលាការអន្តរតូបនីយកម្ម

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ឬវិធានផ្ទៃក្នុង ពុំបានតម្រូវឲ្យចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា ត្រូវតែយកលំនាំតាមយុត្តិសាស្ត្រ ឬវិធានស្តីពីនីតិវិធីរបស់តុលាការអន្តរជាតិ និងតុលាការអន្តរតូបនីយកម្មផ្សេងទៀតនោះទេ ។[៦៤] យុត្តិសាស្ត្រនេះ ពុំបានចងកាតព្វកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា និងតុលាការក្នុងស្រុកដទៃឡើយ ។ ដោយសាររដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា និងវិធានផ្ទៃក្នុង មានបញ្ចូលលិខិតុករណ៍ស្តីពីការការពារសិទ្ធិមនុស្សអន្តរជាតិ ដោយរាប់បញ្ចូលទាំង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងនោះ ដូច្នេះ យុត្តិសាស្ត្រ និងវិធានស្តីពីនីតិវិធីរបស់តុលាការអន្តរជាតិ និងតុលាការអន្តរជាតូបនីយកម្មនានា អាចត្រូវប្រើប្រាស់សម្រាប់ការណែនាំក្នុងការបកស្រាយបញ្ញត្តិច្បាប់អន្តរជាតិផ្សេងៗ ដែលពាក់ព័ន្ធនឹងនីតិវិធីនៅអង្គជំនុំជម្រវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការក្នុងស្រុក ។

[៦៤] ប្រៀបធៀបនឹងអំណះអំណាងខាងលើ ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសេរ៉ាឡេអូន ពាក់ព័ន្ធនឹងការបង្កើតតុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអន, ចុះហត្ថលេខានៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២, បុព្វកថា (បានបញ្ជាក់យ៉ាងជាក់លាក់ថា យុត្តាធិការនៃរបស់ខ្លួនអាចនឹង«ពាក់ព័ន្ធ» ទៅនឹងយុត្តាធិការនៃតុលាការអន្តរជាតិ) ។

អង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា បានលើកយកយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលហៅកាត់ថា "ICC" តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលហៅកាត់ថា "ICTY" តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា "ICTR" តុលាការពិសេសប្រទេសសេរ៉ាឡេអូន ដែលហៅកាត់ថា "SCSL" ក្រុមប្រឹក្សាវិនិច្ឆ័យពិសេសលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរសម្រាប់ប្រទេសទីម័រ "ក្រុមប្រឹក្សាវិនិច្ឆ័យ" "Special Panels" និងស្ថាប័នសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀត រួមមាន តុលាការសិទ្ធិមនុស្សអឺរ៉ុប ហៅកាត់ថា "ECtHR" គណៈកម្មាធិការសិទ្ធិមនុស្ស ហៅកាត់ថា "HRC" និងតុលាការសិទ្ធិមនុស្សអន្តរ-អាមេរិកាំង ដែលហៅកាត់ថា "IACtHR" ជាដើម ។ ជាពិសេស នៅពេលណាដែលពុំអាចរកបាននូវច្បាប់កម្ពុជាដែលពាក់ព័ន្ធ ។ ទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកយកយុត្តិសាស្ត្ររបស់ស្ថាប័នទាំងនោះមកពិចារណានៅពេលធ្វើការវិនិច្ឆ័យ ។ ឧទាហរណ៍ គោលការណ៍នីត្យានុកូលដែលមានចែងក្នុងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[៦៥] និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការបកស្រាយមាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងគោលការណ៍ *អាជ្ញាអស់ជំនុំ*[៦៦] និងផលប៉ះពាល់នៃសេចក្តីថ្លែងការណ៍ជាសាធារណៈដែលចោទប្រកាន់ជនជាប់ចោទណាម្នាក់ដែលមានសិទ្ធិទទួលបានការសន្មតថាជាជនគ្មានទោស ដែលមានចែងក្នុងមាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។[៦៧]

---

[៦៥] *សូមមើល, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ដីកាដំណោះស្រាយ, សូមមើលកំណត់សម្គាល់ជើងទំព័រទី១៩, កថាខណ្ឌ២១៤, ដែលអង្គបុរេជំនុំជម្រះបានអនុវត្តយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដើម្បីបង្ហាញថា បទដ្ឋានអន្តរជាតិនៃនិត្យានុកូលភាពអាចអនុវត្តបាននៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

[៦៦] *ដូចខាងលើ។ កថាខណ្ឌ១២៧-៦០, នៅពេលដែលអង្គបុរេជំនុំជម្រះសំអាងលើការអនុវត្ត និងយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការសិទ្ធិមនុស្សអន្តរ-អាមេរិក ដើម្បីសម្រេចសេចក្តី នោះគោលការណ៍គ្មានការកាត់ក្តីពីរដងលើបទល្មើសតែមួយនឹងពុំត្រូវបានបំពាននោះទេ ។*

[៦៧] *សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក-អជសប/អជតក(១៥), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួនជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិធាន៣៥ សំណើសុំដើម្បីចាត់វិធានការសង្ខេប (ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២) (សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីវិធាន៣៥របស់ នួន ជា") ។ នៅពេលធ្វើការពិចារណាលើការសន្មតទុកមុនថាគ្មានទោសដោយផ្អែកលើសំដីរបស់នាយករដ្ឋមន្ត្រី ដែលបានហៅ នួន ជា ជាសាធារណៈថាជា "ឃាតករ" និង"ជាឧក្រិដ្ឋជននៃអំពើប្រល័យពូជសាសន៍", អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការ*

អ្វីដែលអាចរំពឹងទុក គឺថានឹងមានភាពចន្លោះប្រហោង បើសិនជាពុំមានការជំទាស់ដាច់ខាតដើម្បីឲ្យមានការអនុវត្តយុត្តិសាស្ត្រ ឬការអនុវត្តនីតិវិធីណាមួយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលយោងលើយុត្តិសាស្ត្រ ឬការអនុវត្តពីតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការសិទ្ធិមនុស្សនានា ។ ការទប់ស្កាត់ពីសំណាក់ចៅក្រម និងព្រះរាជអាជ្ញា (និងអាចពីសំណាក់មេធាវីការពារក្តី) អាចនឹងមានន័យថា ច្បាប់កម្ពុជាមិនអាចផ្អែកលើយុត្តិសាស្ត្រក្រៅស្រុកបានទេ ហេតុដូច្នេះយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងពុំត្រូវលើកយកមកប្រើប្រាស់ ។ និយាយមួយបែបទៀត អ្នកទាំងអស់នោះនឹងព្យាយាមធ្វើយ៉ាងណារក្សាលក្ខណៈនៃតុលាការក្នុងស្រុកឲ្យនៅដដែល ហើយការអនុវត្តផ្សេងៗទៀតនៅដូចធម្មតា ។ ទោះបីជាយ៉ាងណាក្តី វាមានសារសំខាន់ណាស់ក្នុងការបញ្ជាក់សាជាថ្មីថា ដោយសារតុលាការជាតិត្រូវបានផ្តល់អាណត្តិឲ្យធ្វើការពិចារណា និងអនុវត្តនូវលិខិតតុបករណ៍ច្បាប់អន្តរជាតិនានាដែលបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ហេតុដូច្នេះសេចក្តីសម្រេច ឬការអនុវត្តនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបញ្ជាក់ថាសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលត្រូវបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញ យ៉ាងហោចណាស់អាចអនុវត្តបាននៅ ក្នុងតុលាការក្នុងស្រុក ។ ចំពោះការអះអាងផ្សេងទៀតដែលផ្ទុយពីនេះ គឺជាការអះអាងដែលពុំមានអំណះអំណាងត្រឹមត្រូវ ជាពិសេសប្រសិនការអះអាងនោះពឹងផ្អែកលើសេចក្តីសម្រេចដែលលើកយកយុត្តិសាស្ត្រពីស្ថាប័នមួយក្នុងចំណោមស្ថាប័នអន្តរជាតិទាំងអស់ខាងលើ ។[៦៨]

---

*សំអាងលើយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គណៈកម្មាធិការសិទ្ធិមនុស្ស តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការសិទ្ធិមនុស្សអន្តរ-អាមេរិក និងតុលាការក្នុងស្រុកមួយចំនួនទៀតដែលរួមមាន ក្រុមប្រឹក្សាឯកជននៃចក្រភពអង់គ្លេស* (United Kingdom's Privy Council) *និងតុលាការកំពូលរបស់សហរដ្ឋអាមេរិក ។ នៅពេលសម្រេចច្រានចោលបណ្តឹងឧទ្ធរណ៍ចំពោះអង្គហេតុនេះអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា*

*«ការជ្រៀតជ្រែករបស់រដ្ឋទៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលមិនទាន់បានសម្រេច តាមរយៈការនិយាយជាសាធារណៈដោយមន្ត្រីក្នុងជួររាជរដ្ឋាភិបាលដែលកំពុងកាន់តំណែងជាផ្លូវការ គឺជាការរំលោភបំពានលើគោលការណ៍សន្មតទុកជាមុនថាគ្មានទោសទាំងនៅក្នុងយុត្តិសាស្ត្ររបស់ស្ថាប័នសិទ្ធិមនុស្ស និងទាំងនៅក្នុងប្រព័ន្ធយុត្តិធម៌ថ្នាក់ជាតិ ។» ដូចខាងលើ។*

[៦៨] *ច្បាប់អន្តរជាតិក៏អាចជាឧបករណ៍សំខាន់សម្រាប់បកស្រាយរដ្ឋធម្មនុញ្ញរបស់រដ្ឋមួយតាមរយៈភាសាសាមញ្ញ និងការសន្ទនា និងផ្តល់ជាយុត្តិសាស្ត្រគំរូ ដែលតុលាការជាតិអាចសិក្សារៀនសូត្រ និងចូលរួមក្នុងការផ្លាស់ប្តូរគំនិតជាសកល ។ សូមមើល,* Martha Davis, *ក្នុងអត្ថបទ Human Rights, Social Justice and State Law: A Manual for Creative Lawyering, ជំពូក១, ទំព័រ២ (រដ្ឋវិស្គីកឈើជ្រុះ ឆ្នាំ២០០៨), អាចរកបាននៅគេហទំព័រ* http://nlginternational.org/hrdocs/NESRI%20legal_training%20_manual.pdf (*ចូលមើលលើកចុងក្រោយនៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២*) ។

## ២.៥) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាតុលាការគំរូ

ជាមួយនឹងសមិទ្ធកម្មដែលថាប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ននៅមានភាពអន់ខ្សោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានគោលបំណងក្នុងការធ្វើជាគំរូសម្រាប់តុលាការក្នុងស្រុក និងដើម្បីឲ្យមានការផ្លាស់ប្តូរមួយក្នុងរយៈពេលវែងស្តីពីការលើកកម្ពស់ និងកសាងសមត្ថភាពប្រព័ន្ធតុលាការនៅក្នុងស្រុក ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងចូលរួមក្នុងការបង្កើត និងបង្ហាញពីការអនុវត្តដ៏ល្អប្រសើរដើម្បីឲ្យតុលាការក្នុងស្រុកយកគំរូតាម និងអនុញ្ញាតឲ្យមានការផ្ទេរនូវចំណេះដឹង និងជំនាញពីសំណាក់សហគមន៍អន្តរជាតិ ។ ដូចដែរ អគ្គលេខាធិការអង្គការសហប្រជាជាតិបានថ្លែងក្នុងអំឡុងពេលនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖

> យើងមានក្តីសង្ឃឹមថា ការបង្កើតឡើងនូវដំណើរការច្បាស់លាស់មួយដែលគោរពតាមបទដ្ឋានអន្តរជាតិ និងជះឥទ្ធិពលផ្អែកអប់រំទៅលើស្ថាប័នដែលកំពុងដំណើរការផ្លូវការបច្ចុប្បន្ន និងបណ្តុះស្មារតីក្នុងចំណោមប្រជាជនទូទៅឲ្យយល់ដឹងពីការពិតពាក់ព័ន្ធនឹងអតីតកាលដែលពោរពេញដោយភាពវិនាសអន្តរាយរបស់កម្ពុជា និងការទាមទារបន្ថែមទៀតឲ្យមានប្រព័ន្ធតុលាការមួយដែលនឹងបំពេញមុខនាទីត្រឹមត្រូវ ។[៦៩]

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានទទួលស្គាល់ម្តងហើយម្តងទៀតអំពីសារៈសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈជាតុលាការគំរូមួយ ដើម្បីបំពេញភាពចន្លោះប្រហោងដែលមាននៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក និងបានកត់សម្គាល់ថា សកម្មភាពរបស់តុលាការនេះនឹងបន្តបង្កើតនូវគំរូសំខាន់សម្រាប់វិស័យយុត្តិធម៌របស់ជាតិ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។[៧០] នៅក្នុងខែធ្នូ ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសរូបនេះ បានសរសេរលិខិតជាលាយលក្ខណ៍អក្សរដាក់ជូននាយក

---

[៦៩] អ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំព្រះរាជាណាចក្រកម្ពុជា, ដកស្រង់ចេញពីអត្ថបទ *Situation of Human Rights in Cambodia*, ដែលដាក់ជូនគណៈកម្មាការសិទ្ធិមនុស្ស, U.N. Doc. E/CN.4/2005/116, កថាខណ្ឌ១៩ (នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៤) ។

[៧០] របាយការណ៍របស់អ្នករាយការណ៍ពិសេសឆ្នាំ២០១១, សូមមើលកំណត់សម្គាល់ជើងទំព័រទី១១, កថាខណ្ឌ៣៨ ។ សូមមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសឆ្នាំ២០១០, សូមមើលកំណត់សម្គាល់ជើងទំព័រទី១១, កថាខណ្ឌ៥៩, អ្នករាយការណ៍ពិសេសបានពិនិត្យឃើញថា:

> មានការរំពឹងទុកថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរតួនាទីជាតុលាការគំរូនៅកម្ពុជា ទើបការអនុវត្តដែលល្អត្រឹមត្រូវអាចចែករំលែកជាមួយប្រព័ន្ធតុលាការ និងអាចជួយលើកស្ទួយការអនុវត្តរបស់ខ្លួនបាន ។ ការដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា មានសក្តានុពលក្នុងការផ្តល់ឱកាសឲ្យចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការផ្ទេរចំណេះដឹងទៅអ្នករួមការងារនៅក្នុងប្រព័ន្ធតុលាការ ។

រដ្ឋមន្ត្រីដើម្បីបង្ហាញអំពីសារៈសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការបង្កើតឲ្យមាននូវគំរូមួយដែលបង្ហាញអំពីការប្តេជ្ញាចិត្តរបស់កម្ពុជានៅចំពោះសហគមន៍អន្តរជាតិដើម្បីធានាឲ្យមានការដាក់ឲ្យទទួលខុសត្រូវចំពោះអំពើឃោរឃៅដែលបានកើតឡើងនៅក្នុងអតីតកាល ដើម្បីការពារសិទ្ធិមនុស្ស និងដើម្បីលើកតម្កើងឯករាជភាពរបស់តុលាការ និងនីតិរដ្ឋ ។[៧១] អង្គជំនុំជម្រះសាលាដំបូង ក៏ធ្លាប់បានទទួលស្គាល់ពីសារៈសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះចំណុចនេះ ដោយបានកត់សម្គាល់ថា "ក្នុងនាមជាតុលាការគំរូ...អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដើរតួនាទីក្នុងការជំរុញ និងសង្កត់ធ្ងន់លើសារៈសំខាន់នៃការពារឯករាជភាព និងសុចរិតភាពនៃប្រព័ន្ធតុលាការ ។[៧២] ដូចគ្នានេះដែរ មន្ត្រីរដ្ឋាភិបាលមួយចំនួនបានបញ្ជាក់ជាច្រើនលើកច្រើនសា ថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការគំរូ ។[៧៣] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានគោលបំណងក្នុងការប្រើប្រាស់លទ្ធភាព ដើម្បីបង្កើនការយល់ដឹងរបស់តុលាការក្នុងស្រុកពាក់ព័ន្ធនឹងបទដ្ឋានអន្តរជាតិ និងការប្រព្រឹត្តទៅនៃការជំនុំជម្រះក្តីដោយយោងតាមគោលការណ៍ទាំងនោះ ។

### ៣) ការទទួលស្គាល់នូវភាពទន់ខ្សោយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ក្រៅពីចេតនាល្អរបស់ចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិករដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមែនអ្វីផ្សេងទៀតសុទ្ធតែល្អទាំងអស់នោះទេ ។ សេចក្តីសម្រេច និងការអនុវត្តដែលបានឆ្លងកាត់ការពិនិត្យពិច័យរបស់អង្គជំនុំជម្រះតុលាការកំពូល ក៏មិនប្រាកដថារួចផុតពីការរិះគន់ ឬការតវ៉ាឡើយ ហើយក៏មិនគួរអនុវត្តដោយធ្វេសប្រហែស ដោយពុំគិតពីតុលាការក្នុងស្រុកនោះទេ ។ ចាំបាច់ត្រូវទាមទារឲ្យមានការប្រុងប្រយ័ត្នដើម្បីធានាថា នឹងពុំមានសេចក្តីសម្រេចដែលត្រូវបានគ្រាន់ទុកជាមុន ឬការអនុវត្តនីតិវិធីដោយអយុត្តិធម៌កើតចេញពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។ ឧទាហរណ៍បើពិនិត្យមើលលើសេចក្តីសម្រេចដោយសំឡេងភាគច្រើនរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០១ បានរកឃើញថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

---

[៧១] របាយការណ៍អ្នករាយការណ៍ពិសេសឆ្នាំ២០១១, សូមមើលកំណត់សម្គាល់ជើងទំព័រទី១១, កថាខណ្ឌ៣៥ ។

[៧២] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តរបស់ក្រុមមេធាវីការពារក្តី អៀង សារី ដែលស្នើសុំដកចៅក្រម និល ណុន, សូមមើលកំណត់សម្គាល់ជើងទំព័រទី៩, កថាខណ្ឌ១៤ ។

[៧៣] សូមមើល, ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន, ពាក្យសំដីនៅក្នុងការក្នុងពិធីធ្វើសម្បថនៃបុគ្គលិកតុលាការជាតិ និងអន្តរជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦, អាចរកបាននៅគេហទំព័រ http://www.eccc.gov.kh/sites/default/files/media/Sok_An_speech_for_reception_3_July_2006.pdf (យើងមានសង្ឃឹម និងរំពឹងទុកយ៉ាងមុតមាំថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងក្លាយជាតុលាការគំរូសម្រាប់កម្ពុជា») ។

កម្ពុជាពុំមានសិទ្ធិអំណាចនៅក្នុងការបញ្ជាឲ្យកាត់បន្ថយកម្រិតទោសរបស់ ឌុច ដោយសារតែមូលហេតុ ឌុច ត្រូវបានឃុំខ្លួនដោយខុសច្បាប់រយៈពេល៨ឆ្នាំ នៅតុលាការយោធានោះទេ ។[៧៤] ដោយសារបញ្ហានៃការឃុំខ្លួនរយៈពេលវែងដោយគ្មានការជំនុំជម្រះនៅកម្ពុជា ត្រូវបានទទួលស្គាល់យ៉ាងជាក់ស្តែងដោយប្រធាននៃអង្គជំនុំជម្រះសាលាដំបូង[៧៥] អង្គជំនុំជម្រះតុលាការកំពូល បានចេញនូវយុត្តិសាស្រ្តមួយដែលបង្ហាញអំពីការព្រួយបារម្ភ ដើម្បីជាសារមួយសម្រាប់ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា និងប្រជាពលរដ្ឋកម្ពុជាដែលបានទទួលរងការចាប់ដាក់ឃុំដោយពុំត្រឹមត្រូវ និងលើសពេលវេលាកំណត់នៅក្នុងដំណាក់កាលមុនអង្គសេចក្តី ដោយប្រព័ន្ធតុលាការជាតិដែលពុំសូវយកចិត្តទុកដាក់ពីដំណើរការនៃការជំនុំជម្រះក្តីប្រកបដោយភាពត្រឹមត្រូវ និងបទដ្ឋាននៃការគោរពសិទ្ធិមនុស្ស ។»[៧៦]

តុលាការក្នុងស្រុកគួរតែមានការប្រុងប្រយ័ត្ន នៅក្នុងការអនុម័តនូវនីតិវិធីមួយចំនួនដែលប្រើប្រាស់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺស្ថាប័នមួយដែលត្រូវទទួលខុសត្រូវលើសកម្មភាពស៊ើបអង្កេតដើម្បីរួមចំណែកក្នុងការបង្ហាញឲ្យឃើញពីការពិត[៧៧] ដោយត្រូវស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ។ ប៉ុន្តែ សម្រាប់ការអនុវត្តជាក់ស្តែង មានលេចចេញនូវសកម្មភាពមួយចំនួនដែលបានបំពានលើវិធានផ្ទៃក្នុង[៧៨] ដោយអ្នកស៊ើបអង្កេត

---

[៧៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ឌុច, *សូមមើលកំណត់សម្គាល់ជើងទំព័រទី ៦*, កថាខណ្ឌ៣៩៥ ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា យុត្តិសាស្រ្តអន្តរជាតិដែលអង្គជំនុំជម្រះសាលាដំបូងបានយកមកប្រើ មិនអាចអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទេ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏គ្មានសិទ្ធិអំណាចក្នុងការផ្តល់ដំណោះស្រាយ ឬកែតម្រូវ នៅពេលដែលពុំមានការរំលោភបំពានលើកិច្ចដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានឡើយ (កថាខណ្ឌ៣៨៩-៩៩) ។ អង្គជំនុំជម្រះតុលាការកំពូលបានដំឡើងកម្រិតផ្តន្ទាទោសពី៣៥ឆ្នាំដែលបានដាក់ដោយអង្គជំនុំជម្រះសាលាដំបូង ទៅកម្រិតទោសជាប់ពន្ធនាគារអស់មួយជីវិត ។ ចៅក្រមអន្តរជាតិចំនួនពីររូបបានបង្ហាញពីការពុំយល់ស្រប ដោយពិនិត្យឃើញថា ការបំពានលើសេរីភាពរបស់ ឌុច គឺ“ជ្រុលហួសហេតុ” ហើយថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា “មានកាតព្វកិច្ចក្នុងការផ្តល់នូវសំណងមួយ” ។ *ដូចខាងលើ*, មតិជំទាស់រួមគ្នារបស់ចៅក្រម Agnieszka Klonowiecka-Milart និងចៅក្រម Chandra Nihal Jayasinghe កថាខណ្ឌ១៤-១៤ ។

[៧៥] របាយការណ៍របស់ Bates, *សូមមើលកំណត់សម្គាល់ជើងទំព័រទី*, នៅទំព័រ៥១, ដោយយោងទៅលើបទសម្ភាសន៍រវាងអ្នកប្រឹក្សាយោបល់មួយរូបជាមួយលោកចៅក្រម និល ណុន ។

[៧៦] របាយការណ៍ OSJI ឆ្នាំ២០១២, *សូមមើលកំណត់សម្គាល់ជើងទំព័រទី*, ទំព័រ១២ ។

[៧៧] វិធានផ្ទៃក្នុង, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៣*, វិធាន ៥៥(៥) ។

[៧៨] *ដូចខាងលើ.*, វិធាន២១(១), វិធាន២៥, វិធាន៥១(៨), វិធាន៥៥(៧) និងវិធាន៦២(៣) ។ វិធានទាំងនេះកំណត់ពីដំណើរការ ដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវតែគោរពតាមនៅពេលធ្វើបទសម្ភាសន៍

នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដូចជា ការពុំបានថតសំឡេងទុកនៅពេលធ្វើសម្ភាសន៍ជាមួយនឹងសាក្សី ហើយពេលខ្លះបង្ហាញឯកសារដល់សាក្សី និងពេលខ្លះទៀត ក្រោយពេលធ្វើសម្ភាសរួចកិច្ចសម្ភាសន៍នោះត្រូវបានសង្ខេបដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយចុះហត្ថលេខាឬផ្តិតស្នាមមេដៃដោយសាក្សី ។ សេចក្តីសង្ខេបនៃបទសម្ភាសន៍ទាំងឡាយដែលបានថតសំឡេងទុកពុំមានយោងទៅរកបទសម្ភាសន៍មុនៗដែលមិនបានថតទុកទេ ដែលនេះបានបង្ហាញឲ្យឃើញអំពីភាពស្រងាកចិត្តដែលថា សេចក្តីសង្ខេបទាំងនោះនឹងពុំឆ្លុះបញ្ចាំងអំពីការធ្វើបទសម្ភាសន៍ដោយស្មោះត្រង់ និងលក្ខណៈបែបបទនៅក្នុងការធ្វើសម្ភាសនោះទេ ។[៧៩] យ៉ាងហោចណាស់មានពេលម្តងនោះ អ្នកស៊ើបអង្កេតបានជួយសម្របសម្រួលចំពោះអ្វីដែលមើលទៅហាក់បីដូចជាការសម្ភាសមួយ "ដែលមានលក្ខណៈគ្រោងទុកជាមុន" ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតបានរៀបចំនូវសំណួរ និងចម្លើយរួចជាស្រេច

---

ជាមួយនឹងសាក្សី រួមមាន ការកត់ត្រាជាលាយលក្ខណ៍អក្សរនៅគ្រប់បទសម្ភាសន៍ ដែលអាចផ្តល់ព័ត៌មានពីថិរវេលានៃការធ្វើសម្ភាស និងបញ្ជាក់ឲ្យបានច្បាស់ពីមូលហេតុនៃការអាក់ខានមិនបានថតសំឡេងនៃបទសម្ភាសន៍ ។

[៧៩] នៅអំឡុងពេលនៃការសួរដេញដោលសាក្សី មាស វឿន ដោយក្រុមមេធាវីការពារ អៀង សារី, សាក្សីរូបនេះបានផ្តល់សក្ខីកម្មថា អ្នកស៊ើបអង្កេតបានមកផ្ទះរបស់គាត់ដើម្បីសម្ភាស គាត់មុនពេលបទសម្ភាសន៍ត្រូវបានថតទុក និងថា "អ្នកស៊ើបអង្កេតនោះបានអានឯកសារមួយចំនួនដោយសង្ខេបៗ ឲ្យខ្ញុំបានដឹងអំពីបទសម្ភាសន៍នេះ ។" សាក្សីក៏បានផ្តល់សក្ខីកម្មបន្ថែមទៀតថា "ប្រពន្ធរបស់ខ្ញុំនៅជិតខ្ញុំ ហើយគាត់នៅទីនោះស្តាប់សំណួរ និងបានរំឭកខ្ញុំពីព្រឹត្តិការណ៍ដែលបានកើតឡើងពីមុនៗ ។" សេចក្តីសង្ខេបជាសំណេរមិនបាននិយាយពីបញ្ហានេះទេ ។ *សំណុំរឿង នួន ជា.*, ០០២/១៩-០៩-២០០៧-អវតក, ប្រតិចារឹក, ទំព័រ៣៥-៣៦ (ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២) ។ *សូមមើល, សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក-អជសដ, សំណើសុំរបស់ អៀង សារី ដែលស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកការបញ្ជាក់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងវត្តមាននៃភ័ស្តុតាងណា ដែលពាក់ព័ន្ធការសួរចម្លើយសាក្សី អឿន តាន់ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨ (ខែសីហា ទី២៩ ឆ្នាំ២០១២); *រឿងក្តី នួន ជា.*, ០០២/១៩-០៩-២០០៧-អវតក-អជសដ, អៀង សារី ស្នើសុំស្តាប់ភ័ស្តុតាងពីអ្នកបកប្រែពាក់ព័ន្ធនឹងការសម្ភាស សាក្សី ភី ភួន ជាលើកទី២ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមានភាពមិនប្រក្រតីកើតឡើងដែលនាំឲ្យមានការនិយាយយករួចខ្លួន (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២) ("សំណើរបស់ ភី ភួន"); *សំណុំរឿង នួន ជា.*, ០០២/១៩-០៩-២០០៧-អវតក-អជសដ, សំណើរបស់ អៀង សារី ដែលទាមទារឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការបញ្ជាក់ពីការិយាល័យសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងការសួរចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ និងចេញដីកាកោះអញ្ជើញអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីផ្តល់ភ័ស្តុតាងពាក់ព័ន្ធនឹងបទសម្ភាសន៍នេះ (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២) ។ ស្រដៀងគ្នានេះដែរ មានគំលាតវត្តុតាងរវាងបទសង្ខេបនៃសក្ខីកម្មមួយចំនួន និងការថតសំឡេងនៃសេចក្តីបំភ្លឺទាំងនោះ ។ *សូមមើល, សំណុំរឿង នួន ជា* ០០២/១៩-០៩-២០០៧-អវតក-អជសដ ។ សំណើសុំលើវិធាន៣៥ ចំពោះការស៊ើបអង្កេតពាក់ព័ន្ធនឹងភាពមិនប្រក្រតីនៅក្នុងកំណត់ត្រាជាសំឡេង និងកំណត់ត្រាជាសំណេរនៃការសម្ភាសសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១) ។

ដោយផ្អែកលើបទសម្ភាសន៍ដែលមិនបានថតទុកកាលពីលើកមុន ហើយសាក្សីបានអានចម្លើយនោះរួចថតចូលក្នុងឧបករណ៍ថតសំឡេង ។[៨០] សេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរ ជាធម្មតាតែងត្រូវបានយកមកប្រើប្រាស់ក្នុងគោលបំណងធ្វើឲ្យសាក្សីចងចាំអំពីព្រឹត្តិការណ៍ឡើងវិញពេលបង្ហាញខ្លួនក្នុងតុលាការ[៨១] ដោយអង្គជំនុំជម្រះ ទទួលស្គាល់ថា អត្ថន័យនៃសេចក្តីសង្ខេបនោះជាសេចក្តីសង្ខេបដែលមានលក្ខណៈ «ស្មោះត្រង់ និងត្រឹមត្រូវ» ដែលឆ្លុះបញ្ចាំងពីបទសម្ភាសន៍ជាក់ស្តែង ។[៨២] អ្វីដែលគួរឲ្យព្រួយបារម្ភជាងនេះទៀតនោះ ព្រះរាជអាជ្ញាបានព្យាយាមស្វែងរកឲ្យមានការប្រើប្រាស់សេចក្តីសង្ខេបទាំងនោះជំនួសឲ្យការផ្តល់សក្ខីកម្មផ្ទាល់មាត់របស់សាក្សី[៨៣] ទោះបីជាវិធីរៀបចំសេចក្តីសង្ខេបទាំងនោះនៅមានលក្ខណៈខ្វះតម្លាភាពនៅឡើយ[៨៤] និងនៅមានលក្ខណៈស្រពិចស្រពិលថាតើ សេចក្តីសង្ខេបទាំងនោះ

---

[៨០] សូមមើល, សំណើសុំរបស់ ភី ភួន, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៧៩*, សេចក្តីផ្តើម, កថាខណ្ឌ៨ ។

[៨១] ឧទាហរណ៍ នៅក្នុងការផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងសារទូរលេខដោយសាក្សី នង សុផង់, សាក្សីបានបញ្ជាក់ថា គាត់មិនបានដឹងច្បាស់ថានរណាជាអ្នកមកប្រមូលទូរលេខនៅគណៈមជ្ឈិមនោះទេ ។ ក្រោយមក ព្រះរាជអាជ្ញាបានប្រើប្រាស់កំណត់ហេតុរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីអានឲ្យសាក្សីស្តាប់ ហើយសាក្សីត្រូវបានសួរថា «សូមមើលឯកសារនេះ ក្រែងអាចជួយរំឭកលោកបានខ្លះៗ» ។ ឆ្លើយតបនឹងសំណើនេះ សាក្សីបាននិយាយថា «ខ្ញុំយល់ស្របចំពោះកំណត់ហេតុស្តាប់ចម្លើយមួយនេះ....ជូនកាលវាត្រូវបានបញ្ជូនតាមរយៈបុរសម្នាក់ដែលមកមន្ទីរនេះ ។» *សំណុំរឿង នួន ជា* ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ១៦-១៨៣ (ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១២) ។

[៨២] *សូមមើល,* សំណុំរឿង នួន ជា ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ២១-២៤ (ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១) (នៅអំឡុងពេលនៃការសួរដេញដោលដោយចៅក្រម Lavergne) ។

[៨៣] *សូមមើល,* សំណុំរឿង នួន ជា ០០២/១៩-០៩-២០០៧-អវតក-អជសដ, សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១ (ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២); សំណុំរឿង នួន ជា ០០២/១៩-០៩-២០០៧-អវតក-អជសដ, សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី២ និងបញ្ជាក់ស្តុតាងពាក់ព័ន្ធនឹងឧបសម្ព័ន្ធសម្ងាត់លេខ I, II, III និងឧបសម្ព័ន្ធសាធារណៈលេខ IV, (ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១២); *សូមមើល,* សំណុំរឿង នួន ជា ០០២/១៩-០៩-២០០៧-អវតក-អជសដ, សំណើសុំបន្ថែមរបស់សហព្រះរាជអាជ្ញាដើម្បីដាក់កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹកជាមួយនឹងឧបសម្ព័ន្ធសម្ងាត់លេខ១ ទៅលេខ ១៦ ជូនអង្គជំនុំជម្រះ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២) ។

[៨៤] ចំណុចនេះក៏ត្រូវបានកត់សម្គាល់ដោយចៅក្រមនៃអង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងសំណុំរឿង០០៣ ដែលបានគូសបញ្ជាក់ថា «វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការស៊ើបអង្កេត នៅមានភាពពុំច្បាស់លាស់នៅឡើយ» ហើយ «មានព័ត៌មានតិចតួចណាស់ដែលត្រូវបានផ្តល់ឲ្យ ដើម្បីអាចយល់បានពីដំណើរការនៃការស៊ើបអង្កេតនេះ ។» *រឿងក្តី* ០០៣/០៧-០៩-២០០៩-អវតក/កសចអ (អបរជ ០២), បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួល

បានឆ្លុះបញ្ចាំងពីការចងចាំពិតប្រាកដរបស់សាក្សីដែរឬយ៉ាងណា ខណៈដែលមានភាពផ្ទុយគ្នាពីការចងចាំដែលបានមកពីការជ្រោមជ្រែង និងជួយសម្រួលដោយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត នៅអំឡុងពេលនៃកិច្ចសម្ភាសន៍ដែលមិនបានថតទុក ។[៨៥]

ទង្វើមួយទៀតដែលតុលាការក្នុងស្រុកមិនគួរយកតម្រាប់តាមនោះ គឺភាពលម្អៀងរបស់អង្គជំនុំជម្រះទៅលើភាគីផ្សេងៗ ដែលនាំឲ្យមានការយល់ឃើញថាអង្គជំនុំជម្រះមិនមានការប្តេជ្ញាចិត្តពេញលេញក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងជាពិសេសសិទ្ធិរបស់ជនជាប់ចោទ ។[៨៦] ឧទាហរណ៍ទាំងនោះរួមមាន អង្គជំនុំជម្រះជារឿយៗបានបិទខ្ទប់សេចក្តីសំណូមពររបស់

---

យកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណី Robert Hamill, មតិជំទាស់របស់ចៅក្រម Lahuis និងចៅក្រម Downing, កថាខណ្ឌ២ (ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១) ។

[៨៥] អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីការស្ទាក់ស្ទើរក្នុងការដោះស្រាយចំណុចចន្លោះប្រហោង ដោយចាត់ទុកសំណួររបស់ក្រុមមេធាវីការពារក្តីសួរទៅសាក្សី ថាជាសំណួរដែលមិនសមស្របក្នុងការចោទសួរទៅកាន់សាក្សីពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃដំណើរការស៊ើបអង្កេត ជាជាងចាត់ទុកថានេះជាការអនុវត្តសិទ្ធិជាមូលដ្ឋានក្នុងការសាកល្បង និងការជជែកតវ៉ាលើភ័ស្តុតាង ។ ឧទាហរណ៍ នៅក្នុងការឆ្លើយតបចំពោះការសួរចម្លើយសាក្សីលើបញ្ហាទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ដោយផ្ទាល់មាត់ថា «សច្ចធារណ៍នៃសុចរិតភាពនៃការស៊ើបអង្កេតក្នុងប្រព័ន្ធតុលាការ» និង «ការស៊ើបអង្កេតត្រូវចាត់ទុកជាចំណុចចាប់ផ្តើម និងអាចជំទាស់បាននៅក្នុងកាលៈទេសៈពិសេសមួយចំនួនតែប៉ុណ្ណោះ ។» អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាក្រុមមេធាវីការពារក្តីគួរតែសួរសំណួរដែលមានពាក់ព័ន្ធនឹងសាក្សី ។ *សំណុំរឿង នួន ជា ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ៤៣-៤៤ (ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១២) (សេចក្តីសម្រេចប្រកាសដោយចៅក្រមCartwright) ។* ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា សាក្សីអាចប្រឆាំងជាមួយនឹងភាពមិនស្របគ្នានៅក្នុងកិច្ចដំណើរការស៊ើបអង្កេត«នៅពេលដែលចាំបាច់ដើម្បីពិនិត្យលើតម្លៃនៃភ័ស្តុតាងនៃសក្ខីកម្មរបស់ពួកគេ ឬដើម្បីការពារភាពយុត្តធម៌នៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។» *សំណុំរឿង នួន ជា ០០២/១៩-០៩-២០០៧-អវតក-អជសដ, សេចក្តីសម្រេចលើសំណើសុំរបស់ នួន ជា ទាក់ទងនឹងការស៊ើបអង្កេតលើភាពមិនស្របគ្នារវាងការថតសំឡេង និងការសរសេរនៃកំនត់ត្រាសម្ភាសរបស់សាក្សីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត, កថាខណ្ឌ ៧ (ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១២) ។*

[៨៦] ភាពលម្អៀងចំពោះភាគី គឺមិនស្របទៅតាមគោលការណ៍អន្តរជាតិនៃការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌នោះទេ ។ ដូចដែលគណៈកម្មការសិទ្ធិមនុស្សនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានពន្យល់ សិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ តម្រូវថា «សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងតុលាការ បានធានាឲ្យមានការតតាំងដែលមានលក្ខណៈស្មើភាពគ្នា ។ មានន័យថា រាល់បុគ្គលគ្រប់រូបទទួលបានសិទ្ធិក្នុងការអនុវត្តនីតិវិធីដូចគ្នា លើកលែងតែមានការបែងចែកដែលមានចែងនៅក្នុងច្បាប់ និងអាចបញ្ជាក់ពីមូលហេតុមិនលម្អៀង និងសមហេតុផល ដែលមិនបង្កឲ្យមានផលវិបាក ឬភាពអយុត្តិធម៌ ចំពោះជនជាប់ចោទ ។» គណៈកម្មការសិទ្ធិមនុស្សនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, CCPR/C/GC/32, មតិទូទៅលេខ៣២, មាត្រា១៤: សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងតុលាការ

ក្រុមមេធាវីការពារក្ដី រារាំងមិនឲ្យពួកគេឆ្លើយតបទៅនឹងការជំទាស់នានា ឬអនុវត្តសិទ្ធិក្នុងការកត់សម្គាល់លើចំណុចសំខាន់ៗ[៨៧] ការអនុញ្ញាតឲ្យសាក្សីសម្រេចចិត្តដោយខ្លួនឯងថាត្រូវឆ្លើយតបទៅនឹងសំណួរពីខាងមេធាវីការពារក្ដី[៨៨] និងចេញសេចក្ដីសម្រេចខុសគ្នាលើមូលហេតុជំទាស់តែមួយ ដោយផ្អែកលើថា

---

និងសិទ្ធិទទួលបានការជម្រះប្រកបដោយយុត្តិធម៌, កថាខណ្ឌ១៣ (ថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០០៧) ។ បន្ថែមពីលើនេះ "លក្ខណៈតម្រូវនៃអព្យាក្រឹតភាពបានបែងចែកជាពីរផ្នែក ។ ទីមួយ ចៅក្រមមិនត្រូវឲ្យសេចក្ដីសម្រេចរបស់ខ្លួនទទួលឥទ្ធិពលពីភាពលម្អៀងផ្ទាល់ខ្លួននោះទេ ឬផ្អែកលើការយល់ឃើញមុនលើរឿងក្ដីណាមួយនោះឡើយ ឬក៏បញ្ចេញអាកប្បកិរិយាមិនសមស្របដែលជួយលើកតម្កើងលើផលប្រយោជន៍របស់ភាគីណាមួយ ដែលអាចធ្វើឲ្យប៉ះពាល់ដល់ភាគីម្ខាងទៀតនោះឡើយ ។ ទីពីរ អង្គជំនុំជម្រះត្រូវតែជាអ្នកពិនិត្យមើលលើភាពសមហេតុផល ដោយពុំមានភាពលម្អៀង" ។ ដូចខាងលើកថាខណ្ឌ២១ ។

[៨៧] សូមមើល, Stuart White, ដកស្រង់ចេញពីអត្ថបទ *Cambodia's Leaders Called out at Khmer Rouge Court*, កាសែតភ្នំពេញប៉ុស្ដិ៍, ថ្ងៃទី១ ខែសីហា ឆ្នាំ២០១២, អាចរកបាននៅគេហទំព័រ http://www.phnompenhpost.com/index.php/KRTalk/cambodias-leaders-called-out-at-khmer-rouge-court.html (ចូលមើលលើកចុងក្រោយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២), បានរាយការណ៍ថាខត្បោសនសព្ទរបស់សហមេធាវីអន្តរជាតិរបស់ជនជាប់ចោទ នួន ជា ត្រូវបានបិទដោយអង្គជំនុំជម្រះសាលាដំបូងបីដងក្នុងពេញដែលកំពុងសួរដេញដោល ។ មានឧទាហរណ៍ជាច្រើនទៀតដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ការអនុវត្តរបៀបនេះ ។ សូមមើល, សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ៧៥-៧៦ (ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២) (ការរារាំងក្រុមមេធាវីការពារក្ដីជនជាប់ចោទមិនឲ្យឆ្លើយតបទៅនឹងការជំទាស់); សូមមើល, សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ៣០-៣១ (ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២) (ការរារាំងក្រុមមេធាវីការពារក្ដីជនជាប់ចោទមិនឲ្យពន្យល់អំពីសំណួរដែលត្រូវសួរ); សូមមើល, សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹត, ទំព័រ៨៧ (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២) (ការរារាំងក្រុមមេធាវីការពារក្ដីមិនឲ្យលើកឡើងពីករណីច្បាប់អន្តរជាតិ), សូមមើល, សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ៨៤-៨៦ (ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣) (ការរារាំងក្រុមមេធាវីការពារក្ដីមិនឲ្យឆ្លើយតបទៅនឹងការចោទប្រកាន់ទាក់ទងនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការត្រួតពិនិត្យសុខភាពរបស់កូនក្ដីខ្លួន) ។

[៨៨] សូមមើល, សេចក្ដីណែនាំរបស់ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន ចំពោះសាក្សី សួង ស៊ីគឿន នៅក្នុងអំឡុងពេលនៃការសួរដេញដោលដោយក្រុមមេធាវីការពារក្ដី អៀង សារី, ០០២/១៩-០៩-២០០៧-អវតក-អជសដ, ប្រតិចារឹក, ទំព័រ៥៣ (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២):

> បើសិនជាលោកគិតថាសំណួរនោះមានភាពច្រំដែល លោកមានសិទ្ធិមិនឆ្លើយ ឬលោកអាចសួរអង្គជំនុំជម្រះ ថាតើលោកគួរឆ្លើយនឹងសំណួរនោះឬក៏អត់...បើសិនជាលោកយល់ថាសំណួរនោះជាសំណួរនាំមុខ លោកអាចរក្សាសិទ្ធិមិនឆ្លើយតបទៅនឹងនោះសំណួរបាន ។

តើសេចក្ដីជំទាស់នោះបានលើកឡើងដោយខាងសហព្រះរាជអាជ្ញា ឬខាងមេធាវីការពារក្ដី ។[៨៩] ការអនុវត្តបែបនេះ បានធ្វើឲ្យប៉ះពាល់ដល់អព្យាក្រឹតភាព និងសុចរិតភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការខ្មែរក្រហម ដោយបង្កើតឲ្យមានជាចម្ងល់ពាក់ព័ន្ធនឹងការប្ដេជ្ញាចិត្តរបស់តុលាការនេះដើម្បីលើកតម្កើងសិទ្ធិទទួលបានការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ដែលខ្លួនបានប្រកាស ។

## ៤) ប្រើប្រាស់ចំណុចវិជ្ជមានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីធ្វើឲ្យទៅជាប្រយោជន៍

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅពុំទាន់បានបង្ហាញអំពីឥទ្ធិពលវិជ្ជមានចំពោះតុលាការក្នុងស្រុកនៅឡើយទេ ។ តាមការពិត សក្ដានុពលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការបំពេញតួនាទីនេះ បាននាំឲ្យមានជាសំណួរចោទឡើងជុំវិញភាពចម្រូងចម្រាសជុំវិញការជំនុំជម្រះក្ដីដែលមានលក្ខណៈនយោបាយទាក់ទងនឹងសវនាការលើសំណុំរឿងរបស់លោក ម៉ម សូណង់ដូ ។ អង្គការសិទ្ធិមនុស្សអន្តរជាតិបានបង្ហាញការព្រួយបារម្ភថា សេចក្ដីសម្រេចនៃរឿងក្ដីនេះនឹងបន្សល់នូវយុត្តិសាស្ត្រមួយ

---

[៨៩] ឧទាហរណ៍ ការបដិសេធមួយចំនួនត្រូវបានលើកឡើងដោយព្រះរាជអាជ្ញានៅក្នុងពេលផ្ដល់សក្ខីកម្មរបស់លោក សួង ស៊ីគឿន នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ ត្រូវបានគាំទ្រដោយអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលហេតុថា សំណួររបស់មេធាវីការពារក្ដីបានធ្វើឲ្យសាក្សីឆ្លើយតាមបែបលក្ខណៈសន្និដ្ឋាន។ *សូមមើល សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក-អជសជ, ប្រតិចារឹក, ទំព័រ៣៦-៥៨ (ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២) ។ សាក្សីត្រូវបានណែនាំមិនឲ្យឆ្លើយតបទៅនឹងសំណួរណាដែលក្រុមមេធាវីការពារក្ដីសួរចាប់ផ្ដើមពីពាក្យ "ប្រសិនបើ" ។ *ដូចខាងលើ,* ទំព័រ៥១ ។ នៅពេលដែលមេធាវីការពារក្ដីបានធ្វើការជំទាស់ដោយផ្អែកលើមូលហេតុដដែល ពួកគេតែងតែត្រូវបានបដិសេធ បើទោះបីជាមានករណីខ្លះមានសេចក្ដីណែនាំពីអង្គជំនុំជម្រះសាលាដំបូង ស្នើឲ្យសាក្សីមិនត្រូវឆ្លើយតាមបែបជាលក្ខណៈសន្និដ្ឋានក៏ដោយ ។ ករណីនេះបានកើតឡើងពាក់ព័ន្ធទៅនឹងការជំទាស់ដែលលើកឡើងដោយមេធាវីរបស់ នួន ជា នៅក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី អែម អឿន ដោយព្រះរាជអាជ្ញា (*សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក-អជសជ, ប្រតិចារឹក, ទំព័រ៣៦-៣៧ (ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១២) និងពាក់ព័ន្ធនឹងការជំទាស់ដែលលើកឡើងដោយក្រុមមេធាវីរបស់ អៀង សារី នៅក្នុងពេលសួរដេញដោលសាក្សី នង សុផង់ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "គ្មានមូលដ្ឋាន" បើទោះបីជា ការឆ្លើយតបនាពេលមុនរបស់សាក្សីមានលក្ខណៈ"ជាការសន្មត" ក៏ដោយ ហើយរំឭកសាក្សីពីកាតព្វកិច្ចរបស់ខ្លួនមិនត្រូវឆ្លើយដោយស្មានៗ (*សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក-អជសជ, ប្រតិចារឹក, ទំព័រ៣៩-៤០ (ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២) ។ អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រការជំទាស់ដែលលើកឡើងដោយព្រះរាជអាជ្ញា ដោយបានរកឃើញថា វាមិនមែនជាការសមស្របនោះទេ ដែលមេធាវីការពារក្ដីព្យាយាមធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមានភាព"ច្របូកច្របល់"ក្នុងអំឡុងពេលសួរដេញដោល ។ *សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក-អជសជ, ប្រតិចារឹត, ទំព័រ៧២-៧៣ (ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១២) ។

ដែលធ្វើឲ្យមានការព្រួយបារម្ភ ចំពោះតម្លៃនៃកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការធ្វើឲ្យប្រសើរឡើងនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌នៅក្នុងតុលាការក្នុងស្រុក ។ អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានកត់សម្គាល់ថា "ការធ្វើជាគំរូល្អរបស់តុលាការខ្មែរក្រហម ស្ថិតនៅឆ្ងាយពីការរំពឹងទុកនៅឡើយ ហើយសាលាក្តីខ្មែរក្រហមប្រហែលជាបានធ្វើអ្វីដែលផ្ទុយពីនេះទៅវិញ ។"[៩០] ស្រដៀងគ្នានេះដែរ លោកស្រី ក្លែរ ដាហ្វ៊ី (Claire Duffy) មកពីអង្គការ Open Society Justice Initiative បានលើកឡើងថា "ស្របពេលដែលតុលាការបានជួយក្នុងការពង្រឹងជំនាញរបស់ចៅក្រម និងមេធាវីក្នុងស្រុក ប្រព័ន្ធនៃតុលាការនេះនៅពុំទាន់មានការផ្លាស់ប្តូរនៅឡើយ ។"[៩១] ប៉ុន្តែ ទោះបីជានៅមានភាពទន់ខ្សោយ និងទទួលរងការរិះគន់ក៏ដោយ ក៏អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅតែជាគំរូដ៏ល្អបំផុតសម្រាប់ការធ្វើកំណែទម្រង់តុលាការ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតុលាការនៅកម្ពុជាដ៏សំខាន់ ។

សេចក្តីសម្រេច និងការអនុវត្តសំខាន់ៗមួយចំនួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលការកម្ពុជាអាចយកមកប្រើប្រាស់ ដើម្បីលើកកម្ពស់សុចរិតភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌក្នុងស្រុក និងពង្រឹងសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ។ សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌គឺជា"ធាតុសំខាន់" នៃការធ្វើឲ្យមាននីតិរដ្ឋ[៩២] ដែលរួមបញ្ចូលនូវគោលការណ៍ដែលមនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់ និងស្ថិតនៅក្រោមច្បាប់ និងគោរពតាមច្បាប់ ។[៩៣] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញឲ្យឃើញនូវសមត្ថភាពក្នុងការបកស្រាយ និងអនុវត្តបទដ្ឋាន

---

[៩០] Peter Zsombor, *ដកស្រង់ចេញពីអត្ថបទ Sonando Verdict a Tough Test for KRT Legacy,* CAMBODIA DAILY ,ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២, ទំព័រ១-២, ដកស្រង់ពីលោក Rupert Abbott, Amnesty International's Asia Researcher for Cambodia, ដោយផ្អែកលើសម្តីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Ban Ki-Moon ថាគាត់នឹងមិនអនុញ្ញាតឲ្យមានសំណុំរឿង០០៣ និង០០៤នោះទេ ។

[៩១] ដូចខាងលើ, ទំព័រ២ ។

[៩២] ដូចដែលបានរៀបរាប់ដោយចៅក្រមជាន់ខ្ពស់ Lord Bingham នៅក្នុងអត្ថបទបំភ្លឺរបស់គាត់, THE RULE OF LAW 90 (Penguin Books ២០១១) ។

[៩៣] ចៅក្រម Bingham បានបកស្រាយគោលការណ៍ "នីតិរដ្ឋ" ដែលតម្រូវថា "ប្រជាជន និងអាជ្ញាធរទាំងអស់ដែលនៅក្នុងរដ្ឋ ទោះបីជាស្ថិតនៅក្នុងស្ថាប័នរដ្ឋ ឬស្ថាប័នឯកជន ត្រូវបានចងកាតព្វកិច្ច និងទទួលបានអត្ថប្រយោជន៍ពីច្បាប់ដែលត្រូវបានបង្កើតឡើងជាសាធារណៈ ដែលមានអានុភាព (ទូទៅ) សម្រាប់ពេលអនាគត និងត្រូវបានប្រើប្រាស់ជាសាធារណៈដោយតុលាការ ។" ដូចខាងលើ, ទំព័រ៨ ។

អន្តរជាតិនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ជាពិសេសពាក់ព័ន្ធនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(ICCPR)ដែលជាផ្នែកមួយដ៏សំខាន់បំផុតនៃតម្លៃនៃកេរដំណែលរបស់ខ្លួន ។[៩៤]

នៅក្នុងដំណាក់កាលមុនសវនាការ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស្តីពីបញ្ហាពាក់ព័ន្ធនឹងការសុំនៅក្រៅឃុំ និងលក្ខណៈវិនិច្ឆ័យសំខាន់ៗដើម្បីធ្វើយុត្តិកម្មចំពោះការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយយោងតាមសិទ្ធិក្នុងការទទួលបានសេរីភាពដូចមានចែងនៅក្នុងមាត្រា៩នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) គឺជាគោលការណ៍ណែនាំសម្រាប់តុលាការក្នុងស្រុក ។ ឧទាហរណ៍ នៅក្នុងសំណុំរឿង០០១ អង្គបុរេជំនុំជម្រះបានបញ្ជាក់លើបណ្តឹងឧទ្ធរណ៍ថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើរូបជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច មាន«សារៈសំខាន់»ពាក់ព័ន្ធនឹងមាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងវិធានផ្ទៃក្នុង ក្រោយពីធ្វើការពិចារណាយ៉ាងល្អិតល្អន់លើយុត្តិកម្មដែលបានប្រើប្រាស់ជាមូលដ្ឋាននៃការឃុំខ្លួន ។[៩៥] ទោះបីជានៅក្នុងច្បាប់ក្នុងស្រុកមានចែងអំពីការសុំនៅក្រៅឃុំដោយមាន

---

[៩៤] ការិយាល័យឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិដើម្បីសិទ្ធិមនុស្ស បានរៀបរាប់ថា កេរដំណែល គឺជាទស្សនៈវិស័យយ៉ាងសំខាន់មួយរបស់តុលាការចម្រុះ ក្នុងការចូលរួមដើម្បីពង្រឹង«នីតិរដ្ឋនៅក្នុងសង្គមមួយ តាមរយៈការអនុវត្តការជំនុំជម្រះក្តីដែលមានប្រសិទ្ធិភាព ដើម្បីបញ្ចប់វប្បធម៌និទ្ទណ្ឌភាព ព្រមទាំងពង្រឹងសមត្ថភាពតុលាការ ។» *សូមមើល* ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ហៅកាត់ថា (OHCHR), ដកស្រង់ពី *Rule of Law Tools in Post Conflict States: Maximizing the Legacy of Hybrid Courts,* United Nations, ៤-៥ (២០០៨), *អាចរកបាននៅគេហទំព័រ* www.ohchr.org/Documents/Publications/HybridCourts.pdf *(ចូលមើលចុងក្រោយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២) ។*

[៩៥] បណ្តឹងឧទ្ធរណ៍របស់ ឌុច ប្រឆាំងទៅនឹងសេចក្តីសម្រេចស្តីពីការឃុំខ្លួនបណ្តោះអាសន្ន, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១២,* កថាខណ្ឌ៥៧ ។ អង្គបុរេជំនុំជម្រះបានរកឃើញថា ការឃុំខ្លួនបណ្តោះអាសន្នដោយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជាវិធានចំបាច់មួយដើម្បីបញ្ចៀសកុំឲ្យជនជាប់ចោទដាក់សម្ពាធលើសាក្សី ឬជនរងគ្រោះ; ដើម្បីបញ្ចៀសការបំផ្លាញភស្តុតាង; ដើម្បីធានាពីវត្តមានរបស់ជនជាប់ចោទក្នុងដំណើរការតុលាការ; ដើម្បីការពារសុវត្ថិភាពរបស់ជនជាប់ចោទ; និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។ ការលើកឡើងពីហេតុផលសម្រាប់ការឃុំឃាំងបណ្តោះអាសន្នដោយយោងលើវិធាន៦៣(៣)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានរកឃើញថា ហេតុផលក្នុងការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នជារឿងត្រឹមត្រូវ ពីព្រោះបើសិនជាដោះលែង ជនជាប់ចោទអាចនឹងគំរាមកំហែងសាក្សី *(ដូចខាងលើ ។* កថាខណ្ឌ៣៤); វាជាការសំខាន់ដែលសាក្សីមិនមានការភ័យខ្លាច និងមិនទទួលរងសម្ពាធដោយសារការផ្តល់សក្ខីកម្ម *(ដូចខាងលើ ។* កថាខណ្ឌ៣៦); វាអាចជាហានិភ័យដែលជនជាប់ចោទអាចនឹងបាត់ខ្លួន *(ដូចខាងលើ ។* កថាខណ្ឌ៣៩); បើសិនជាគាត់ត្រូវដោះលែង វានឹងអាចជាហានិភ័យចំពោះសុវត្ថិភាពរបស់ជនជាប់ចោទពីសំណាក់ជនរងគ្រោះ, សាច់ញាតិបងប្អូន និងអតីតអ្នកធ្វើការនៅក្នុងគុកស-២១ *(ដូចខាងលើ ។* កថាខណ្ឌ៤៣); និង ផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យ, ចំណាប់អារម្មណ៍

ការធានាក៏ដោយ[៩៦] ក៏ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជានៅតែបន្តពឹងផ្អែកលើការដាក់ពន្ធនាគារ ដែលជាជំហរដាច់ណាត់សម្រាប់ជនជាប់ចោទដែលរង់ចាំការជំនុំជម្រះក្តី ហើយសំណើសុំនៅក្រៅឃុំដោយមានការធានា កម្រនឹងទទួលបានការអនុញ្ញាតណាស់ ។[៩៧] សវនាការស្តីពីការស្នើសុំនៅក្រៅឃុំនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាឧទាហរណ៍មួយយ៉ាងសំខាន់សម្រាប់តុលាការក្នុងស្រុក នៅពេលដែលព្រះរាជអាជ្ញាត្រូវតែស្វែងរកហេតុផលដ៏រឹងមាំសម្រាប់ការឃុំខ្លួន ហើយមេធាវីការពារក្តីត្រូវមានសមត្ថភាព (និងកាតព្វកិច្ច) ក្នុងការបង្ហាញអំពីអំណះអំណាង និងការជជែកតវ៉ាយ៉ាងម៉ត់ចត់ចំពោះមូលដ្ឋាននៃការឃុំឃាំង រីឯចៅក្រមត្រូវតែពិនិត្យពិច័យលើសេចក្តីសំអាងហេតុទាំងនោះឲ្យបានគ្រប់

---

របស់ប្រជាជនខ្មែរ និងក្រុមសារព័ត៌មានមកលើដំណើរការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, និងការយល់ដឹងជាសាធារណៈនៃអត្តសញ្ញាណរបស់ជនជាប់ចោទ ដែលនាំឲ្យការដោះលែងជនជាប់ចោទអាចនឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ (*ដូចខាងលើ* ។ កថាខណ្ឌ៥០, ៥២, ៥៥) ។

[៩៦] មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា “ជាគោលករណ៍ ជនជាប់ចោទនៅតែជាជនដែលមានសេរីភាព” ប៉ុន្តែ “លើកលែងតែ” ជននោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន នៅក្រោមលក្ខខណ្ឌនៃក្រមនីតិវិធី ។ មាត្រា២០៤ បានចែងថាការឃុំខ្លួនបណ្តោះអាសន្នអាចនឹងត្រូវធ្វើឡើង ចំពោះបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមដែលពាក់ព័ន្ធនឹងកម្រិតទោសជាប់ពន្ធនាគារចាប់ពីមួយឆ្នាំឡើងទៅ ។ មាត្រា២០៥ បានចែងថាការឃុំខ្លួនបណ្តោះអាសន្នអាចនឹងត្រូវធ្វើឡើងនៅពេលដែល“ចាំបាច់” ដើម្បីបញ្ចៀសកុំឲ្យបទល្មើសកើតមានឡើងម្តងទៀត, ដើម្បីការពារសាក្សី ឬរក្សាភស្តុតាង ឬការបង្ហាញ, ដើម្បីធានាវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការ, ឬដើម្បីការពារសុវត្ថិភាពរបស់ជនជាប់ចោទ ឬសណ្តាប់ធ្នាប់សាធារណៈ ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, អនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

[៩៧] *Joint Cambodian NGO Report on Torture and Other Cruel, Inhuman or Degrading Treatment or Punishment in the Kingdom of Cambodia,* ដាក់ជូនគណៈកម្មការអង្គការសហប្រជាជាតិប្រឆាំងនឹងការដាក់ទណ្ឌកម្ម, កិច្ចប្រជុំលើកទី៤៥/ U.N. Doc. CAT/C/45/1, at 4-5 (Nov. 1, 2010)/ អាចរកបាននៅគេហទំព័រ http://tpocambodia.org/uploads/media/Joint_Cambodian_NGO_CAT_Report_06-10-10_English.pdf (ចូលមើលលើកចុងក្រោយនៅថ្ងៃទី១ ខែវិច្ឆកា ឆ្នាំ២០១០); Cambodian Center for Human Rights, *Fourth Bi-Annual Report: Fair Trial Rights* ២០០៩-២០១១ (២០១២), ទំព័រ១៧-២០, *អាចរកបាននៅគេហទំព័រ* http://www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=81&id=5 (ចូលមើលលើកចុងក្រោយនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១០) ។ The Center for Social Development's Court Watch Project ("CWP") រាយការណ៍ថា នៅក្នុងការឃ្លាំមើលរឿងក្តីដោយអង្គការ CWP តុលាការកម្រដោះលែងជនជាប់ចោទក្រោយពីការបង្ហាញខ្លួនលើកដំបូងណាស់ បើទោះបីជារឿងក្តីនោះពាក់ព័ន្ធនឹងបទល្មើសកម្រិតស្រាលក៏ដោយ ។ Court Watch Bulletin ២០០៦, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១០*, នៅទំព័រ៨ ។

ជ្រុងជ្រោយ និងចេញសេចក្ដីសម្រេចមួយដែលមានសំអាងហេតុសមរម្យ ដោយផ្អែកលើការសន្មតពីសេរីភាពថាជាចំណុចចាប់ផ្ដើម ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតយុត្តិសាស្ត្រដ៏មានសារប្រយោជន៍មួយចំនួន ស្ដីពីលក្ខខណ្ឌដែលដាក់ឲ្យជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួន ដោយរាប់បញ្ចូលទាំងការកំហិតរបស់តុលាការពាក់ព័ន្ធនឹងការទាក់ទងរវាងជនជាប់ចោទជាមួយភរិយា[៩៨] និងសិទ្ធិរបស់ជនជាប់ចោទដែលត្រូវបានឃុំខ្លួន ដើម្បីចូលមើលឯកសារក្នុងសំណុំរឿងដោយអនុលោមតាមសិទ្ធិក្នុងការចូលរួមក្នុងការការពារខ្លួន និងដើម្បីធានាអំពីភាពស្មើគ្នាក្នុងការតតាំងក្ដីជាមួយនឹងព្រះរាជអាជ្ញា ។[៩៩] សេចក្ដីសម្រេចដែលមានសារៈសំខាន់មួយទៀតនោះ គឺក្រមនីតិវិធីព្រហ្មទណ្ឌបានហាមប្រាមមេធាវីមិនឲ្យផ្ដល់សំណៅឬផ្នែកណាមួយនៃឯកសារក្នុងសំណុំរឿងទៅកូនក្ដីរបស់ខ្លួន[១០០] ដែលបង្កឲ្យមានការព្រួយបារម្ភជាខ្លាំង

---

[៩៨] *សំណុំរឿង នួន ជា., ០០២/១៩-០៩-២០០៧-អវតក*/PCOJ (PCOJ05), *សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការទាក់ទងរវាងជនជាប់ចោទ និងភរិយារបស់ខ្លួន, កថាខណ្ឌ១៨ (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨) (រកឃើញថាសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បញ្ឈៀសទំនាក់ទំនងរវាងជនជាប់ចោទ អៀង សារី ជាមួយប្រពន្ធរបស់គាត់ជនជាប់ចោទ អៀង ធីរិទ្ធិ មិនត្រូវបានពន្យល់ហេតុផលឲ្យបានគ្រប់គ្រាន់នោះទេ ជាពិសេសមិនបានពន្យល់ថាតើការកំណត់ទំនាក់ទំនងគឺជាវិធានការសមាមាត្រចំបាច់ក្នុងការពារផលប្រយោជន៍នៃការស៊ើបអង្កេតដែរឬយ៉ាងណា) ។ អង្គបុរេជំនុំជម្រះ ក៏បានរកឃើញដែរថា ជនជាប់ចោទគួរត្រូវបានអនុញ្ញាតឲ្យជួបគ្នាដោយអនុលោមតាមវិធានដែលអនុវត្ត នៅពេលស្ថិតនៅក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្ន ។ ដូចខាងលើ ។ កថាខណ្ឌ២១ ។*

[៩៩] *សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក-កសចអ, សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីបង្គាប់ឲ្យចូលមើលឯកសារសំណុំរឿងដោយជនជាប់ឃុំ (ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩) ។ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានអនុវត្តយុត្តិសាស្ត្រពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលទទួលស្គាល់ថា "មាននិន្នាការកំពុងកើនឡើងសម្រាប់តុលាការដែលទទួលស្គាល់ថា សិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមក្នុងការការពារក្ដីរបស់ខ្លួន និងសិទ្ធិទទួលការតតាំងដោយស្មើភាពគ្នា ជាមួយនឹងការចោទប្រកាន់ដែលតម្រូវឲ្យមានកម្រិតជាក់លាក់មួយ នៃការទទួលបានសិទ្ធិក្នុងការចូលមើលឯកសារភស្ដុតាងដោយ "ផ្ទាល់ និងពេញចិត្ត" ពីសំណាក់ជនជាប់ចោទ ។" ដូចខាងលើ ។ កថាខណ្ឌ១១ ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតទទួលយកសំណើរបស់ក្រុមមេធាវីការពារក្ដី ដោយដាក់ចេញនូវគោលការណ៍ទូទៅមួយដែលអនុញ្ញាតឲ្យជនជាប់ចោទអាចចូលមើលឯកសារស្ដីពីសំណុំរឿង នៅខណៈពេលដែលកំពុងរង់ចាំការជំនុំជម្រះនៅក្នុងមន្ទីរឃុំឃាំង ។ ដូចខាងលើ ។ កថាខណ្ឌ១៥ ។*

[១០០] ក្រមនីតិវិធីព្រហ្មទណ្ឌ, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៩៦*, មាត្រា១៤៩ (បានចែងថា មេធាវីអាចអានផ្នែកណាមួយនៃឯកសារក្នុងសំណុំរឿងជូនកូនក្ដីខ្លួនបាន ប៉ុន្តែមិនត្រូវឲ្យសំណៅឯកសារដែលពាក់ព័ន្ធទៅនឹងផ្នែកនោះទៅឲ្យកូនក្ដីខ្លួននោះទេ) ។

ទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងចូលរួមក្នុងការការពារខ្លួនរបស់ពួកគេ ជាពិសេសជនជាប់ចោទទាំងឡាយដែលពុំទាន់មានអ្នកតំណាង ។[១០១]

ការតម្រូវឲ្យចៅក្រមត្រូវតែចេញសេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថាជា "ការគោរពនូវសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌"[១០២] គឺជាយុត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់តុលាការក្នុងស្រុក ដែលជារឿយៗការផ្តល់សំអាងហេតុរបស់តុលាការនៅមានលក្ខណៈពុំទាន់ពេញលេញ ឬពេលខ្លះពុំមានតែម្តង ។ សេចក្តីសម្រេចជាច្រើនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្ហាញអំពីសមត្ថភាពរបស់តុលាការនេះក្នុងការធ្វើការប្រកបដោយឯករាជ្យ មិនលម្អៀង និងការវិភាគយ៉ាងល្អិតល្អន់អំពីគោលការណ៍ច្បាប់អន្តរជាតិដែលមានលក្ខណៈស្មុគស្មាញ ជាជាងការទទួលយកភ្លាមៗនូវការបកស្រាយចំពោះអត្ថន័យនៃបទបញ្ញត្តិទាំងនោះដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃផ្សេងទៀត ។ ឧទាហរណ៍ នៅក្នុងការពិចារណាអំពីភាពចម្រូងចម្រាសនៃការពង្រីកទម្រង់នៃសហឧក្រិដ្ឋកម្មរួម ("សហឧក្រិដ្ឋកម្មរួមប្រភេទទី៣") ថាជាទម្រង់មួយនៃការ

---

[១០១] នៅកម្ពុជា មិនមែនជនជាប់ចោទដែលមានជីវភាពខ្វះខាត់ខ្សោយគ្រប់រូបសុទ្ធតែមានសិទ្ធិក្នុងការទទួលបានមេធាវីដោយតុលាការនោះទេ ។ មាត្រា៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ការជ្រោមជ្រែងពីមេធាវី ត្រូវមានចាំបាច់ដោយខានមិនបាន ប្រសិនបើជារឿងក្តីពាក់ព័ន្ធទៅនឹងបទល្មើសឧក្រិដ្ឋ ឬជនជាប់ចោទនោះជាអនីតិជន ។ ក្រមនីតិវិធីព្រហ្មទណ្ឌ, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៩៦* ។ នៅក្នុងរឿងក្តីភាគច្រើនដែលត្រូវបានពិនិត្យដោយ CWP នៅក្នុងឆ្នាំ២០០៦ ជនជាប់ចោទមិនត្រូវបានតំណាងពីមេធាវីការពារក្តីក្នុងពេលណាមួយនៃដំណាក់ការស៊ើបអង្កេតនោះទេ ហើយមានតែត្រឹម ៤៦ភាគរយតែប៉ុណ្ណោះដែលទទួលបានតំណាងនៅក្នុងការជំនុំជម្រះក្តី ។ បើទោះបីជានៅក្នុងករណីដែលមេធាវីការពារក្តីត្រូវបានចាត់តាំងនៅក្នុងការស៊ើបអង្កេតក៏ដោយ ពួកគេត្រូវបានចាត់តាំង"នៅនឹងកន្លែង" ហើយមិនអាចត្រៀមលក្ខណៈបានគ្រប់គ្រាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតនោះទេ ។ ព្រឹត្តិបត្រឃ្លាំមើលតុលាការឆ្នាំ២០០៦, *សូមមើលកំណត់សម្គាល់ជើងទំព័រទី១០*, ទំព័រ៤ ។

[១០២] *សូមមើល*, សំណុំរឿង នួន ជា បណ្តឹងឧទ្ធរណ៍ស្តីពីវិធាន៣៦, *សូមមើលកំណត់សម្គាល់ជើងទំព័រទី៦៧*, កថាខណ្ឌ២៥ ។ ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ដែលប្តឹងដោយក្រុមមេធាវីការពារក្តីរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធលើសំណើសុំទាក់ទងនឹងវិធាន៣៥ ដែលស្នើឲ្យមានការដាក់ទណ្ឌកម្មចំពោះសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីពាក់ព័ន្ធនឹងជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលដំបូង ដែលបានបដិសេធលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី គឺជា"សេចក្តីប្រកាសដែលពុំមានសមត្ថកិច្ច និងពុំមានសំអាងហេតុគ្រប់គ្រាន់" (ដូចខាងលើ ។ កថាខណ្ឌ២៦) និងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលសម្រេចថា សំណើនោះពុំអាចទទួលយកបាន "នៅខណៈដែលវាបានរារាំងក្រុមមេធាវីការពារក្តីមិនចូលប្តឹងឧទ្ធរណ៍បាន" (ដូចខាងលើ។ កថាខណ្ឌ២៩) ។

ទទួលខុសត្រូវ អង្គបុរេជំនុំជម្រះបានធ្វើការវិភាគស៊ីជម្រៅអំពីសមត្ថកិច្ចដែលធ្លាប់បានយកមកប្រើប្រាស់ពីពេលមុនដើម្បីគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋរួមប្រភេទទី៣ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាជាងការទទួលយកភ្លាមៗនូវអំណះអំណាងរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គូស្លាវីលើបញ្ហាដូចគ្នានេះ ។[១០៣] ចំណុចនេះបានបង្ហាញពីភាពផ្ទុយគ្នាទៅនឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលរកឃើញថា ទំនួលខុសត្រូវប្រភេទនេះអាចអនុវត្តបាននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយធ្វើការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមប្រភេទទីបី មិនបានឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥ ដល់១៩៧៩ នោះឡើយ ។[១០៤] អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រចំពោះសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។[១០៥]

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានបកស្រាយយ៉ាងទូលំទូលាយអំពីសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយយោងតាមយុត្តិសាស្ត្រអន្តរជាតិ អាចជាគំរូសម្រាប់តុលាការក្នុងស្រុក ។ ឧទាហរណ៍ ទាក់ទងនឹងការពិចារណាលើសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ត្រៀមដើម្បីការពារខ្លួន និងសិទ្ធិក្នុងការទំនាក់ទំនងជាមួយមេធាវី ដែលខ្លួនបានជ្រើសរើសដោយយោងតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អង្គបុរេជំនុំជម្រះបានបង្គាប់ថា ដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបដិសេធមិនឲ្យក្រុមមេធាវីការពារក្តីធ្វើការថតសំឡេងពីជំនួបរវាង ជនជាប់ចោទ និងមេធាវីរបស់ខ្លួននៅមន្ទីរឃុំឃាំង

---

[១០៣] សំណុំរឿង នួន ជា., ០០២/១៩-០៩-២០០៧-អវតក/កសចអ (អបរជ៣៥), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម (JCE) (ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០) ។ ដូចដែលបានពិនិត្យ អាជ្ញាធរពឹងផ្អែកលើអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) នៅក្នុងរឿងក្តី *Prosecutor v. Tadić* ពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមប្រភេទទី៣ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ពួកគេពុំមានភស្តុតាងគ្រប់គ្រាន់ពាក់ព័ន្ធនឹងការអនុវត្តជាក់លាក់របស់រដ្ឋ ឬគំនិតយោបល់របស់គណៈវិនិច្ឆ័យនៅពេលដែលពាក់ព័ន្ធទៅនឹងរឿងក្តី០០២ ។ ដូចខាងលើ ។ កថាខណ្ឌ៧៧ ។

[១០៤] ដូចខាងលើ ។ កថាខណ្ឌ៨៨ ។

[១០៥] សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសដ, សេចក្តីសម្រេចនៅការអនុវត្តសហឧក្រិដ្ឋកម្មរួម (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) ។

បានរំលោភបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ ។[១០៦] យោងតាមយុត្តិសាស្រ្តនៃតុលាការសិទ្ធិមនុស្សនៃអឺរ៉ុប អង្គបុរេជំនុំជម្រះបានស្រាយយ៉ាងក្បោះក្បាយលើមាត្រា ១៤ ដោយសម្រេចថា វិធីដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអនុវត្តសិទ្ធិនេះក្នុងន័យចង្អៀតគឺ«ពុំស្របនឹងកម្មវត្ថុ និងគោលបំណងនៃការធានាការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ទេ ។»[១០៧] ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចដ៏សំខាន់មួយទៀតស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមក្នុងសវនាការ[១០៨] និងនីត្យានុកូលក្នុងការបន្តឃុំឃាំងដោយគ្មានការជំនុំជម្រះក្តី[១០៩] ដែលអាចនឹងអនុវត្តដោយតុលាការក្នុងស្រុក ដើម្បីពង្រឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជាប់ចោទ ។

ការអនុវត្តជាច្រើនដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់ អាចនឹងយកមកប្រើប្រាស់នៅតុលាការក្នុងស្រុកដើម្បីបំពេញបន្ថែមនូវចំណុចដែលសវនាការក្នុងស្រុកអាក់ខានមិនបានអនុវត្តន៍តាមបទដ្ឋានអន្តរជាតិដែលបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញ ។ ការអនុវត្តប្រភេទនេះរួមមាន

---

[១០៦] សំណុំរឿងនួនជា,០០២/១៩-០៩-២០០៧-អវតក/កសចអ(អបរជ ៦៨) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍, របស់ អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធចំពោះសំណើសុំដើម្បីថតសំឡេង/វីដេអូនៃអំឡុងពេលនៃការជួបគ្នាជាមួយ អៀង សារី នៅក្នុងមណ្ឌលឃុំឃាំង (ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១០) ។

[១០៧] ដូចខាងលើ ។ កថាខណ្ឌ៣១ ។

[១០៨] សំណុំរឿង នួន ជា, ០០២/១៩-០៩-២០០៧-អវតក/អជសជ ការវាយតម្លៃសុខភាពជនជាប់ចោទសាជាថ្មីក្នុងការចូលរួមក្នុងសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១, កថាខណ្ឌ១៨-២១ (ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៣) ។ ផ្អែកលើយុត្តិសាស្រ្តរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងគណៈវិនិច្ឆ័យពិសេស, អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីពីការរកឃើញរបស់ខ្លួន ដែលជានជាប់ចោទ អៀង ធីរិទ្ធ ពុំមានកាយសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងការកាត់ក្តីបានទេ ។

[១០៩] ដូចខាងលើ ។ កថាខណ្ឌ ១៩-២៣, អង្គជំនុំជម្រះវិសាមញ្ញបានធ្វើការពិចារណាលើយុត្តិសាស្រ្តរបស់តុលារព្រហ្មទណ្ឌអន្តរជាតិ តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការកំពូលរបស់សហរដ្ឋអាមេរិក នៅក្នុងការពិចារណាពីភាពស្របច្បាប់នៃការបន្តឃុំខ្លួន អៀង ធីរិទ្ធ ដោយសំអាងទៅលើការការពារអន្តរជាតិប្រឆាំងទៅនឹងការឃុំខ្លួនដោយមិនមានពេលកំណត់ និងសិទ្ធិទទួលបានជំនុំជម្រះដោយគ្មានការពន្យារពេល ។ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យមានការដោះលែង អៀង ធីរិទ្ធ ជាបន្ទាន់ ដោយផ្អែកលើមូលហេតុថា គ្មានមូលដ្ឋានសម្រាប់បន្តឃុំខ្លួនគាត់បន្តទៀត ។ ដូចខាងលើ ។ កថាខណ្ឌ៣០ ។ សេចក្តីសម្រេចនេះត្រូវបានប្តឹងទៅអង្គជំនុំជម្រះតុលាការកំពូល ដោយការិយាល័យសហព្រះរាជអាជ្ញា ប៉ុន្តែនៅខណៈពេលដែលកំពុងសរសេរអត្ថបទនេះ អង្គជំនុំជម្រះតុលាការកំពូលពុំទាន់ចេញសេចក្តីសម្រេចនៅឡើយទេ ។

សមត្ថភាពរបស់ភាគីក្នុងការជំទាស់ទៅនឹងសំណួរ[១១០] ការអនុវត្តវិធានស្តីពីភស្តុតាង[១១១] និងការបង្កើតយន្តការដែលអនុញ្ញាតឲ្យមានការវាយតម្លៃ និងការបដិសេធភស្តុតាង ។[១១២] ដោយសារតែក្រមនីតិវិធីព្រហ្មទណ្ឌចែងត្រឹមតែថា តុលាការក្នុងស្រុកនឹងពិចារណាលើភស្តុតាងដែលដាក់ជូនអង្គជំនុំជម្រះដើម្បីធ្វើការវាយតម្លៃដោយផ្អែកលើ“ការសម្រេចចិត្តរបស់ចៅក្រម”[១១៣] ទើបការអនុវត្តបែបនេះនឹងអាចជាគំរូសំខាន់មួយនៅក្នុងការកំហិតការប្រើប្រាស់ភស្តុតាងដើម្បីធានាការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

## ៥) បន្ទាប់ពីទីនេះ តើចំណុចណាដែលត្រូវបន្តដំណើរទៅ?

នេះជាពេលវេលា ដែលត្រូវចាប់ផ្តើមគិតពីមធ្យោបាយដែលអាចឲ្យតុលាការក្នុងស្រុកប្រើប្រាស់ចំណុចវិជ្ជមាននៃយុត្តិសាស្រ្ត និងយន្តការទាក់ទងនឹងនីតិវិធីដែលបង្កើតឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីធ្វើឲ្យក្លាយទៅជាប្រយោជន៍ និងបង្កើតវិធីដែលអាចបញ្ចូលការ

---

[១១០] នៅពេលដែលវិធានផ្ទៃក្នុងមិនបានបញ្ចូល សិទ្ធិដើម្បីលើកឡើងពីការជំទាស់ វាបានក្លាយជាបទដ្ឋានក្នុងការអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាំងពីការចាប់ផ្តើមដំណើរការដំបូង ។

[១១១] វិធាន៨៧(២) នៃវិធានផ្ទៃក្នុង បានចែងថា “គ្រប់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវតែផ្អែកលើភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវដាក់ឲ្យមានការសួរដេញដោល ។” យោងតាមវិធាន៨៧(៣) អង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិក្នុងការបដិសេធចំពោះសំណើសុំដាក់ភស្តុតាងនៅពេលដែលសំណើនោះមិនបានបំពេញតាមលក្ខខណ្ឌតម្រូវជាក់លាក់មួយចំនួន ដូចជា ករណីដែលភស្តុតាងដែលមិនជាប់ពាក់ព័ន្ធ ឬភស្តុតាងស្ទួន មិនអាចបង្ហាញពីការពិត ឬច្បាប់មិនអនុញ្ញាត ។ ឱកាសសម្រាប់ភាគីក្នុងការបដិសេធចំពោះភស្តុតាងដែលអនុលោមទៅតាមលក្ខខណ្ឌទាំងនោះ គឺជាបុរេលក្ខខណ្ឌសម្រាប់ការទទួលយកភស្តុតាងថ្មីដែលដាក់ជូនអង្គបុរេជំនុំជម្រះផងដែរ ។ *សូមមើល សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧-អវតក/អជសជ, សេចក្តីសម្រេចពាក់ព័ន្ធឯកសារថ្មី និងបញ្ហាពាក់ព័ន្ធដទៃទៀត (ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២) ។ នៅពេលដែលលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញទាក់ទងនឹងការទទួលយកភស្តុតាង អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាលើតម្លៃ និងទម្ងន់នៃភស្តុតាងដើម្បីឲ្យស្របទៅនឹងលក្ខខណ្ឌទាំងនោះ ។ *សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ “ឌុច”* ០០១,១៨-០៧-២០០៧-អវតក/អជសជ, សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃឯកសារដែលមានក្នុងសំណុំរឿងធ្វើជាភស្តុតាង, កថាខណ្ឌ៧ (ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩) ។

[១១២] ឧទាហរណ៍ អង្គបុរេជំនុំជម្រះបានរកឃើញថា ឯកសារដែលទទួលបានតាមរយៈការធ្វើទារុណកម្មមិនអាចយកមកសំអាងដើម្បីស្វែងរកការពិតបានទេ ។ *សំណុំរឿង នួន ជា,* ០០២/១៩-០៩-២០០៧/កសចអ (អបជវ ៣១), សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើសុំទាក់ទងនឹងផ្សៀងផ្ទាត់ និងការពឹងផ្អែកលើភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម, កថាខណ្ឌ៣៨ (ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០) ។

[១១៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, *សូមមើលកំណត់សម្គាល់ជើងទំព័រទី ៩៦*, មាត្រា៣២១ ។

អនុវត្តន៍ទាំងនេះបាន ។ ដើម្បីអាចធ្វើដូច្នេះបាន គឺតម្រូវឲ្យមានការចូលរួមរបស់រាជរដ្ឋាភិបាល ព្រមទាំងការប្តេជ្ញាចិត្ត ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធតុលាការទាំងមូលប្រកបដោយអត្ថន័យ និងមាននិរន្តរភាព ព្រមជាមួយនឹងវត្ថុបំណងដ៏សំខាន់បំផុតដើម្បីធ្វើដំណើរឆ្ពោះទៅរកការធ្វើឲ្យមាននីតិរដ្ឋនៅកម្ពុជា ។

សន្និសីទដែលប្រមូលផ្តុំទៅដោយអ្នកជំនាញគួរតែត្រូវរៀបចំឡើង ដោយមានការចូលរួមជាគំនិត និងកិច្ចសហប្រតិបត្តិការពីសំណាក់អ្នកពាក់ព័ន្ធគ្រប់កម្រិត ដែលរួមមានក្រុមប្រឹក្សាសម្រាប់កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក្រសួងយុត្តិធម៌ ចៅក្រមជាតិ ព្រះរាជអាជ្ញា និងមេធាវី តំណាងអង្គការក្រៅរដ្ឋាភិបាល និងអ្នកជំនាញអន្តរជាតិ រួមមានអ្នកជំនាញពីគ្រប់អង្គភាព និងគ្រប់ផ្នែកនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ចៅក្រម មេធាវីការពារក្តី និងព្រះរាជអាជ្ញា) ។ សន្និសីទនេះត្រូវធ្វើឡើងដើម្បីរិះរកបញ្ហាដែលមាននៅក្នុងប្រព័ន្ធតុលាការបច្ចុប្បន្ន[១១៤] និងដើម្បីស្វែងរកវិធីសាស្ត្រ និងដំណោះស្រាយសម្រាប់ដោះស្រាយបញ្ហាទាំងអស់នោះ ដើម្បីរិះរកចំណុចទូទៅ និងទស្សនវិជ្ជមានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការអនុវត្តនៅក្នុងតុលាការក្នុងស្រុក[១១៥] ព្រមទាំងបង្កើតគម្រោងសកម្មភាពមួយដើម្បីកំណត់ពីវិធីសាស្ត្រមួយដែលអាចផ្ទេរ និងអាចឲ្យតុលាការក្នុងស្រុកទាញយកចំណុចវិជ្ជមានពីយុត្តិសាស្ត្រ និងយន្តការទាក់ទងនឹងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមានលក្ខណៈស៊ីសង្វាក់គ្នា ។

បន្ទាប់ពីសន្និសីទនេះ ក្រុមការងារមួយគួរតែត្រូវបានបង្កើតឡើង ដោយមានបញ្ចូលនូវសមាសភាពមេធាវី ចៅក្រម និងព្រះរាជអាជ្ញា ទាំងជាតិ និងអន្តរជាតិ ។ ក្រុមការងារទាំងនេះ គួរធ្វើការពិនិត្យពិច័យដោយប្រុងប្រយ័ត្នលើចំណុចវិជ្ជមាន និងអវិជ្ជមាន ដែលកើតចេញពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងរិះរកចំណុចផ្សេងៗដែលចូលរួមចំណែកលើកស្ទួយសិទ្ធិទទួលបានការជំនុំជម្រះ

---

[១១៤] វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា ចំណុចខ្សោយទាំងនេះនៅក្នុងបរិបទនៃប្រទេសកម្ពុជា គឺត្រូវបានដឹងឮជាទូទៅ និងជាក់ស្តែង (ដូចដែលបានរៀបរាប់ពីខាងដើមនៅក្នុងអត្ថបទនេះ) និងត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយភ្នាក់ងារសង្កេតការណ៍ជាច្រើន និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើផ្នែកព្រហ្មទណ្ឌយុត្តិធម៌ ។ នៅពេលខាងមុខពុំចាំបាច់ត្រូវរិះរកបញ្ហាទាំងនេះបន្តទៀតនោះទេ ។ អ្វីដែលប្រសើរនោះគឺ គួរតែផ្តោតលើការបង្កើតចំណេះដឹងដើម្បីរិះរកមធ្យោបាយល្អៗដើម្បីប្រើប្រាស់យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្វើជាប្រយោជន៍ដើម្បីបំពេញចំណុចខ្វះខាត ។

[១១៥] ទស្សនៈវិស័យវិជ្ជមានមួយចំនួនស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអាចយកមកប្រើប្រាស់នៅក្នុងស្រុកត្រូវបានរកឃើញនៅខែកញ្ញា ឆ្នាំ២០១២ ក្នុងកិច្ចប្រជុំស្តីពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានចូលរួមដោយក្រុមការងារជាច្រើន ហើយជជែកលើប្រធានបទផ្សេងៗ គ្នារួមមានកេរដំណែលនៃយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេរៀនស្តីពីការឃ្លាំមើលតុលាការ និងការងារស្តីពីការចងក្រងឯកសារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ប្រកបដោយយុត្តិធម៌ និងសមស្របដែលអាចអនុវត្តន៍បានដោយតុលាការក្នុងស្រុក ដើម្បីបំពេញបន្ថែមលើចំណុចខ្សោយដែលត្រូវបានដឹងឮ និងកត់ត្រាទុកនៅក្នុងប្រព័ន្ធតុលាការនាពេលបច្ចុប្បន្ន ។ ក្រុមការងារនេះគួរតែកោះប្រជុំដើម្បីរិះរកបំលាស់ប្តូរនីតិកម្ម និងនីតិវិធីដែលចាំបាច់សម្រាប់ឲ្យតុលាការក្នុងស្រុកយកទៅអនុវត្តន៍ឲ្យស្របតាមគោលការណ៍អន្តរជាតិ ដោយមានការជ្រោមជ្រែងពីយុត្តិសាស្រ្ត និងការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ កិច្ចការនេះគួរតែត្រូវធ្វើឡើងដោយមានការត្រួតពិនិត្យលើគ្រប់ច្បាប់ដែលពាក់ព័ន្ធនឹងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល ជាជាងពិនិត្យមើលតែទៅលើផ្នែកណាមួយនៃច្បាប់ និងដើម្បីធានាថាការផ្លាស់ប្តូរដែលបានស្នើឡើងត្រូវតែស្របនឹងបរិបទច្បាប់ទាំងមូល និងមានភាពស៊ីចង្វាក់គ្នាទៅនឹងការផ្លាស់ប្តូរលើច្បាប់មួយដាច់ដោយឡែក ។[១១៦] បន្ទាប់មក ក្រុមការងារនេះ គួរតែបញ្ជូនអនុសាសន៍របស់ខ្លួនជូនទៅរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីត្រួតពិនិត្យ និងផ្តល់យោបល់ ដោយមានកំណត់ពេលវេលាច្បាស់លាស់សម្រាប់ធ្វើការឆ្លើយតប និងបង្កើតជាយុត្តិសាស្រ្តសម្រាប់សកម្មភាពនាពេលអនាគត ។

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក្រសួងយុត្តិធម៌ និងភាគីដែលពាក់ព័ន្ធនៅកម្រិតថ្នាក់ជាតិ ត្រូវតែជួយ និងចូលរួមនៅគ្រប់សន្និសីទជាមួយនឹងក្រុមការងារនោះ ដើម្បីឲ្យខ្លួនមានអារម្មណ៍ថាជាម្ចាស់លើដំណើរការនៃការធ្វើកំណែទម្រង់ ដោយការទទួលរ៉ាប់រងដោយខ្លួនឯង ។ ដំណាក់កាលចុងក្រោយ នឹងតម្រូវឲ្យរាជរដ្ឋាភិបាលជួយសម្រួលក្នុងការអនុវត្តន៍វិធានការទាំងឡាយទទួលបានពីការផ្តល់អនុសាសន៍តាមរយៈក្រសួងយុត្តិធម៌ ។ គោលបំណងចម្បងនៃដំណើរការនេះ គឺដើម្បីធានាថាចំណុចវិជ្ជមាននៃយុត្តិសាស្រ្តនិងយន្តការនានាទាក់ទងនឹងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចអនុវត្តបានដោយមានលក្ខណៈដូចគ្នា និងស្របគ្នា ដោយតុលាការក្នុងស្រុកដើម្បីពង្រឹងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសមត្ថភាពនៃស្ថាប័នតុលាការ ។ គោលការណ៍ច្បាប់ទាំងនេះត្រូវតែអនុវត្តនៅគ្រប់សាលកវិទ្យាល័យច្បាប់ និងស្ថាប័នបណ្តុះបណ្តាលផ្នែកច្បាប់ និងតុលាការ

---

[១១៦] សារប្រយោជន៍នៃយុត្តិសាស្រ្តរួមដើម្បីធ្វើកំណែទម្រង់ច្បាប់ត្រូវបានរកឃើញនៅអំឡុងពេលនៃការធ្វើកំណែទម្រង់ប្រជាធិបតេយ្យនៃប្រទេសដែលទើបតែងើបពីសង្រ្គាម ។ ឧទាហរណ៍ តាមរយៈការងារនៃគណៈកម្មការវិសោធនកម្មច្បាប់ Brčko (“BLRC”) នៅប្រទេសបូស្នៀ និងហឺហ្សេហ្គោវីណា (Bosnia and Herzegovina) បានកំណត់ថា ប្រព័ន្ធតុលាការ និងព្រហ្មទណ្ឌយុត្តិធម៌ទាំងមូលត្រូវតែរៀបចំសាជាថ្មី, គណៈកម្មការនេះ បានយកវិធីសាស្រ្តពិនិត្យជារួមលើច្បាប់ដែលពាក់ព័ន្ធទៅនឹងស្ថាប័នមួយ ជាជាងពិនិត្យលើច្បាប់នីមួយៗដាច់ដោយឡែក ដើម្បីធានាពីការផ្លាស់ប្តូរដែលបានស្នើឡើងឲ្យស្រប និងសមជាមួយនឹងក្របខណ្ឌច្បាប់ជារួម ។ មើល Michael G. Karnava, *Creating the Legal Framework of the Brčko District of Bosnia and Herzegovina: A Model for the Region and Other Postconflict Countries*, 97 AM. J. INT’L L. 111, 116 (2003) ។

ទាំងអស់ ដើម្បីបណ្តុះបណ្តាលមេធាវី ចៅក្រម និងព្រះរាជអាជ្ញា នៅកម្ពុជាស្តីពីការប្រើប្រាស់យុត្តិសាស្ត្រ និងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ៦) សំឡេងគ្រែបន្ទឹហៅមេធាវីការពារជនជាប់ចោទ

ពុំមានមូលហេតុផលណាមួយដែលមេធាវីការពារក្តីដែលកំពុងអនុវត្តន៍កិច្ចការនៅក្នុងតុលាការក្នុងស្រុក ត្រូវទន្ទឹងរង់ចាំរាជរដ្ឋាភិបាលដើម្បីចាត់វិធានការនោះទេ ។ មេធាវីខ្លួនឯងផ្ទាល់ ត្រូវតែដើរតួនាទីជាទ័ពស្រួចក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងត្រូវត្រួសត្រាយផ្លូវក្នុងដំណើរការកំណែទម្រង់នេះ ដោយកំណត់បទដ្ឋានច្បាប់អន្តរជាតិ និងបទបញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងតុលាការជាតិឲ្យមានភាពស៊ីសង្វាក់គ្នា ។ នៅពេលណាក៏ដោយឲ្យតែអាចអនុវត្តន៍បាន អំណះអំណាងពាក់ព័ន្ធនឹងសិទ្ធិទាំងនេះគួរតែត្រូវផ្សារភ្ជាប់ជាមួយនឹងយុត្តិសាស្ត្រ និងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រសិនបើ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បកស្រាយសិទ្ធិជាក់លាក់ណាមួយដែលមានដើមកំណើតចេញពីរដ្ឋធម្មនុញ្ញនោះសេចក្តីយោងត្រូវតែយោងទៅរករដ្ឋធម្មនុញ្ញ ដោយបញ្ជាក់ប្រាប់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាតុលាការក្នុងស្រុក ដោយត្រូវចងភ្ជាប់កាតព្វកិច្ចដោយរដ្ឋមធ្មនុញ្ញ និងត្រូវគោរពតាមរដ្ឋធម្មនុញ្ញ ។ ប្រសិនបើការអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តម្រូវឲ្យមានការផ្តល់សំអាងហេតុពេញលេញនៅពេលចេញសេចក្តីសម្រេច ហេតុអ្វីមេធាវីការពារក្តីត្រូវខ្វាសអៀនក្នុងការទាមទារឲ្យចៅក្រមក្នុងស្រុកបំពេញកាតព្វកិច្ចដូចគ្នា? ប្រសិនបើ ព្រះរាជអាជ្ញាបានសន្ទនាជាលក្ខណៈឯកជនជាមួយចៅក្រមជំនុំជម្រះស្តីពីសំណុំរឿង មិនថាពាក់ព័ន្ធនឹងបញ្ហាអង្គហេតុ ឬបញ្ហារដ្ឋបាលទេ មេធាវីការពារក្តីត្រូវចង្អុលបង្ហាញថា អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ធ្លាប់បានកត់សម្គាល់ហើយថា ការទាក់ទងតែភាគីម្ខាងរវាងចៅក្រមជំនុំជម្រះ និងព្រះរាជអាជ្ញាគួរតែត្រូវជៀសវាង ដោយសារការទាក់ទងនេះ “អាចបង្កើតទំនាក់ទំនងមិនស្មើគ្នារវាងព្រះរាជអាជ្ញា និងចៅក្រមជម្រះក្តី ។”[១១៧]

មេធាវីការពារក្តីគួរតែចាប់ផ្តើមត្រួតពិនិត្យមើលសេចក្តីសម្រេច និងការអនុវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីរិះរកសេចក្តីសម្រេច និងការអនុវត្តណាដែលអាចយកមកប្រើប្រាស់បាន នៅក្នុងការជួយជ្រោមជ្រែងឲ្យមានការគោរពសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយ

---

[១១៧] *សំណុំរឿង នួន ជា., ០០២/១៩-០៩-២០០៧/អវតក-អជសង/អជតក(១២), សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងប្តឹងជំទាស់ចិត្តចៅក្រម* Silvia Cartwright, *កថាខណ្ឌ២៧ (ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០) ។*

យុត្តិធម៌របស់កូនក្តីខ្លួន ។ សូមចាំថា មិនមែនគ្រប់យុត្តិសាស្ត្រ ឬយន្តការទាក់ទងនឹងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងអស់សុទ្ធតែអាចចូលមើលបាននោះទេ ដូច្នេះគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាអាច ឬគួរតែជួយជ្រោមជ្រែងនៅក្នុងការធ្វើកិច្ចការទាំងនេះ ។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គួរតែជ្រើសរើសក្រុមមេធាវីមួយក្រុមដើម្បីធ្វើការជាមួយក្រុមឃ្លាំមើលតុលាការ ដើម្បីរិះរកសេចក្តីសម្រេច និងនីតិវិធីសំខាន់ៗបំផុតដែលអាចឲ្យមេធាវីការពារក្តីប្រើប្រាស់ដើម្បីធ្វើការតស៊ូមតិនៅក្នុងសំណុំរឿងរបស់ពួកគេបាន ។

មេធាវីការពារក្តីអាចដើរតួនាទីនាំមុខក្នុងការធ្វើ "អន្តរតូបនីយកម្ម" លើសំណុំរឿងក្តីក្នុងស្រុកតាមរយៈតុលាការកម្ពុជា ដោយការតស៊ូមតិដោយពុំមានការខ្លាចរអា និងដោយមានភាពជឿជាក់ ដើម្បីធ្វើឲ្យតុលាការក្នុងស្រុកបើកសវនាការ ដែលស្របតាមគោលការណ៍ជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ដែលបានអនុវត្ត និងបកស្រាយដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចមានចែងនៅក្នុងវដ្តធម្មនុញ្ញ លើយុត្តិសាស្ត្រ និងការអនុវត្តនីតិវិធីដែលត្រូវបានជ្រើសរើសយកមក ។